

ការសិក្សាស្រាវជ្រាវថ្នាក់ជាតិ ស្តីពីសុខភាព និងបទពិសោធ ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា

របាយការណ៍សង្ខេប

๒

អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា អំពើហិង្សាលើស្ត្រីគឺជាបញ្ហាសង្គម និងមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ហើយវាគឺជាឫសគល់មួយដែលនាំឈានទៅរកវិសមភាពយេនឌ័រ។ ផលវិបាកនៃបញ្ហានេះផ្នែកសង្គមនិងផ្នែកសុខភាពកំពុងទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំង។ អំពើហិង្សាមិនត្រឹមតែប៉ះពាល់ដល់ស្ត្រីដែលជាអ្នករួចផុតពីគ្រោះថ្នាក់ប៉ុណ្ណោះទេ តែវាក៏មានផលប៉ះពាល់ដល់កុមារដែលប្រឈមមុខនឹងបញ្ហានេះ និងសហគមន៍ទាំងមូលផងដែរ។ ដំណោះស្រាយបញ្ហានេះ ទាមទារឱ្យមានការឆ្លើយតបជាអន្តរវិស័យនិងគ្រប់លំដាប់ថ្នាក់ ការពន្យល់បង្ហាញនូវកស្តុតាងច្បាស់លាស់ និងគំរូនៃ ការអនុវត្តដ៏ល្អបំផុតកម្រិតអន្តរជាតិ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានទៅមុខយ៉ាងរឹងមាំ ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី រាប់បញ្ចូលទាំង ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទីពីរ(២០១៤-២០១៨)។ជាលទ្ធផលការសិក្សាស្រាវជ្រាវលក្ខណៈប្រជាសាស្ត្រដោយសម្ភាស តាមគ្រួសារ ត្រូវបានរៀបចំ និងប្រកាសផ្សព្វផ្សាយក្នុងឆ្នាំ២០១៤ ដើម្បីពង្រឹងនូវកស្តុតាងជាមូលដ្ឋាន និង ជាព័ត៌មានសម្រាប់ការរៀបចំសកម្មភាពនាពេលអនាគត និងដើម្បីសម្របទៅតាមស្តង់ដារនៃវិធីសាស្ត្រ របស់អង្គការសុខភាពពិភពលោកក្នុងការប្រមូលទិន្នន័យ ព្រមទាំងដើម្បីប៉ាន់ប្រមាណក្នុងលំដាប់ថ្នាក់ជាតិ នូវ អត្រាប្រ៉ាឡង់ មូលហេតុ និងផលវិបាកនៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ។

វិធីសាស្ត្ររបស់អង្គការសុខភាពពិភពលោក ត្រូវបានរៀបចំឡើងសម្រាប់ការសិក្សាស្រាវជ្រាវស្តីពីសុខភាព និងអំពើហិង្សាលើស្ត្រី ជាលក្ខណៈពហុប្រទេស (ឆ្នាំ២០០៥) ត្រូវបានទទួលស្គាល់ថាជានិយាមមាសដ៏មានតម្លៃ ដើម្បីជាមធ្យោបាយវាស់វែងពីអំពើហិង្សាលើស្ត្រី។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយវិធីសាស្ត្រនេះត្រូវបានអនុវត្តនៅបណ្តាប្រទេសមួយចំនួន ក្នុងកម្រិតតំបន់ និងសាកលលោក។ បម្រែបម្រួលនៃអត្រាប្រ៉ាឡង់ ពីពេលវេលាមួយទៅពេលវេលាមួយទៀតបានបង្ហាញថា អំពើហិង្សាមិនមែន មិនអាចចៀសវាងបាននោះទេ ប៉ុន្តែវាអាចបង្ការទប់ស្កាត់បាន ហើយអាចកាត់បន្ថយផលប៉ះពាល់របស់វាបាន។ ទិន្នន័យដែលមានសុពលភាព ហើយអាចធ្វើការប្រៀបធៀបបាន គឺជាមូលដ្ឋាននៃការរៀបចំ គោលនយោបាយ និងសកម្មភាពបានយ៉ាងត្រឹមត្រូវ ។

នៅព្រះរាជាណាចក្រកម្ពុជា ការសិក្សាស្រាវជ្រាវនេះត្រូវបានចងក្រងជាឯកសារយ៉ាងសុក្រិត អំពីទំហំ និងសភាពនៃអំពើហិង្សាផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត ដែលស្ត្រីបានជួបប្រទះ។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ស្ត្រីមានហានិភ័យខ្លាំងជាមួយនឹងអំពើហិង្សាពីដៃគូស្និទ្ធស្នាល ហើយអំពើហិង្សាតែងកើតឡើងយ៉ាងញឹកញាប់ និងមានសភាពធ្ងន់ធ្ងរទៀតផង។ ក្នុងចំណោមស្ត្រីដែលបានរាយការណ៍ថា ធ្លាប់បានទទួលរងរបួសស្នាមដោយសារអំពើហិង្សាពីដៃគូ ពួកគាត់ស្ទើរតែទាំងអស់ (៩០%) បានរាយការណ៍ថា ធ្លាប់ទទួលរងការឈឺចាប់ខ្លាំង ដល់កម្រិតមួយដែលត្រូវការសេវាថែទាំសុខភាព។ ក្នុងខណៈពេលដែលអំពើហិង្សាលើស្ត្រីត្រូវបានរាយការណ៍តែក្នុងកម្រិតមួយដែលនៅទាប ហើយផលវិបាកផ្នែក សុខភាពរបស់វាត្រូវបានទទួលស្គាល់តិចតួច ការសិក្សាស្រាវជ្រាវបានរកឃើញថា ស្ត្រីនៅព្រះរាជាណាចក្រកម្ពុជាប្រឈមនឹងផលប៉ះពាល់ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសុខភាពបន្តពូជដែលបណ្តាលមកពី ផលវិបាកនៃអំពើហិង្សា ។ អំពើហិង្សាពីដៃគូស្និទ្ធស្នាល គឺមិនត្រឹមតែបណ្តាល

ឱ្យមានការគំរាមកំហែងដល់ សុខភាពសាធារណៈប៉ុណ្ណោះទេ គឺថែមទាំងជាបញ្ហាមួយដែលមនុស្ស ជាច្រើនបានទទួលស្គាល់។ការសិក្សាស្រាវជ្រាវបានបញ្ជាក់ថាស្ត្រីដែលបានរាយការណ៍ពីបទពិសោធ នៃអំពើហិង្សាដែលគាត់បានជួបប្រទះ ភាគច្រើនគាត់តែងនិយាយរឿងនេះប្រាប់សមាជិកគ្រួសារគាត់ ឬអ្នកជិតខាងផងដែរ។ ហេតុនេះ ចលនាសង្គមអាចធ្វើឱ្យបញ្ហានេះត្រូវបានគេមើលឃើញនិង ដឹងកាន់តែច្រើន ហើយសហគមន៍ក៏កាន់តែយល់ដឹងថា អំពើហិង្សាជាទង្វើដែលមិនអាចទទួលយក បានឡើយ។

យើងសង្ឃឹមថា ព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះ នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការងារបង្ការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីប្រកប ដោយប្រសិទ្ធភាព និងធ្វើឱ្យប្រសើរឡើងនូវសេវាទាំងឡាយសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេស ស្ត្រីដែល ទទួលរងគ្រោះដោយអំពើហិង្សា ។

យើងសូមសម្តែងការវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្ត កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូយ៉ាងល្អ របស់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានាដែលបានរួមចំណែកចូលរួមក្នុងដំណើរការ នៃការសិក្សាស្រាវជ្រាវនេះ ។ ក្នុងនាមគណៈកម្មការដឹកនាំ ក្រសួងកិច្ចការនារី មានមោទនភាព ក្នុងការពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់ព្រមទាំងជានាឱ្យមាន ការតាមដានប្រកបដោយប្រសិទ្ធភាព លើការអនុវត្តអនុសាសន៍នានាដែលកើតចេញពីការសិក្សា ស្រាវជ្រាវនេះ ។

សូមមេត្តាបន្តធ្វើការទាំងអស់គ្នា ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី
រដ្ឋមន្ត្រី
ក្រសួងកិច្ចការនារី
ព្រះរាជាណាចក្រកម្ពុជា

٣٤%

អំពើហិង្សាលើស្ត្រី (VAW) នៅក្នុងទម្រង់ និងការសម្តែងចេញជាច្រើនរបស់វា នៅក្នុងគ្រប់បរិយាកាសទាំងអស់ គឺជាការរំលោភបំពានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ នៅជុំវិញពិភពលោក ស្ត្រីជាច្រើនធ្លាប់មានបទពិសោធនរងនូវអំពើហិង្សា មិនថាពួកគេស្ថិតក្នុងអាយុវ័ណ្ណៈ ជាតិសាសន៍ និងជាតិពន្ធអ្វីនោះឡើយ។ អំពើហិង្សាទាំងនេះ ភាគច្រើនគឺត្រូវបានជំរុញដោយសារតែពួកគេជាស្ត្រី និងទាក់ទងនឹងតួនាទីផ្នែកយេនឌ័រនៅក្នុងសង្គម។ ភាគច្រើនលើសលប់នៃអំពើហិង្សាលើស្ត្រី គឺត្រូវបាន

នៃស្ត្រី ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើយទៅ នៅទូទាំងសាកលលោក ធ្លាប់រងនូវអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទក្នុងជីវិតរបស់ពួកគេ (DEVRIES ET AL., 2013; WHO, 2013)។

**យោងទៅលើក្នុងសន្និដ្ឋានជាទូទៅក្នុងពិភពលោកនាពេលបច្ចុប្បន្ន*

ប្រព្រឹត្តិដោយបុរស ហើយជារឿយៗ បុរសនោះគឺជាដៃគូជិតស្និទ្ធរបស់ស្ត្រី។ យោងតាមការប៉ាន់ប្រមាណកម្រិតសាកលលោកដែលទើបបានធ្វើឡើងនាពេលថ្មីៗនេះបង្ហាញថា ៣៥% នៃស្ត្រី ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើយទៅ នៅទូទាំងសាកលលោក ធ្លាប់រងនូវអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទក្នុងជីវិតរបស់ពួកគេ (Devries et al., 2013; WHO, 2013)។ អំពើហិង្សាដែលប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ គឺជាបុព្វហេតុនាំមុខគេមួយ ដែលធ្វើឲ្យមានការសម្លាប់

មនុស្សជាស្ត្រីនៅទូទាំងពិភពលោក (Stockl et al., 2013) ហើយនិងមានផលវិបាកផ្នែកសុខភាពរយៈពេលខ្លី និងរយៈពេលវែងធ្ងន់ធ្ងរជាច្រើនទៀត (WHO, 2013)។ ការចំណាយផ្នែកសេដ្ឋកិច្ច និងសង្គម ទាក់ទងនឹងអំពើហិង្សាលើស្ត្រី (VAW) គឺមានចំនួនច្រើនគួរឲ្យកត់សម្គាល់ ហើយកស្តុតាងកម្រិតសាកលលោកបានបង្ហាញថា អំពើហិង្សា ជានិច្চកាលតែងបំផ្លិចបំផ្លាញដល់កិច្চខិតខំក្នុងការអភិវឌ្ឍនៅកម្រិតផ្សេងៗ ដោយវាជះឥទ្ធិពលដល់រាងកាយមនុស្ស និងមូលធនសង្គម (WHO, 2005)។

ក្នុងប្រទេសកម្ពុជា ស្ថានភាព ការស្រាវជ្រាវស្តីពីអំពើហិង្សាលើស្ត្រី បានចង្អុលបង្ហាញឲ្យឃើញនូវបទពិសោធអំពើហិង្សាយ៉ាងសាយភាយនៅទូទាំងប្រទេស (CDHS, 2012; Fulu et al., 21013)។ ស្ត្រីនៅក្នុងវប្បធម៌ និងវណ្ណៈទាំងអស់ គឺជាកម្មវត្ថុនៃអំពើហិង្សាផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច ក្នុងទម្រង់ជាច្រើន។ អំពើហិង្សាទាំងនេះ រួមមានទាំងអំពើហិង្សាដែលប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ការរំលោភសេព និងការធ្វើបាបផ្លូវភេទ ការបៀតបៀនផ្លូវភេទ ការវាយប្រហារដោយទឹកអាស៊ីត និងការជួញដូរ (MoWA, 2008)។

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី តាមរយៈការដាក់ឲ្យមានកំណែ ទម្រង់ផ្នែកច្បាប់ និងគោលនយោបាយជាច្រើន រួមទាំងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងផែនការសកម្មភាពជាតិ។ ប្រទេសកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបញ្ឈប់អំពើហិង្សាលើស្ត្រី (VAW) តាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិមនុស្សអន្តរជាតិជាច្រើន។[1] បន្ថែមលើនេះទៀត មានការទទួលស្គាល់យ៉ាងទូលំទូលាយក្នុងចំណោមអ្នកដឹកនាំរាជរដ្ឋាភិបាលថាការមានទិន្នន័យប្រកបដោយគុណភាពស្តីពីអត្រា និងសុខភាព និងវិបាកដទៃទៀតបង្កឡើងដោយ VAW ទម្រង់ផ្សេងៗ គឺមានភាពចាំបាច់ណាស់ដើម្បីបង្កើនការយល់ដឹងជាព័ត៌មានសម្រាប់ការធ្វើកម្មវិធី និងគោលនយោបាយដែលផ្អែកលើភស្តុតាង រួមទាំងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) និងដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៅក្នុងការអនុវត្តអន្តរាគមទាំងនេះផងដែរ។

នៅចន្លោះឆ្នាំ ២០១៤-២០១៥ ដើម្បីបំពេញចន្លោះប្រហោងផ្នែកចំណេះដឹងដែលត្រូវបានកំណត់ឃើញ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការគាំទ្រពីអង្គការសុខភាពពិភពលោក (WHO) និងអង្គការ UN Women បានធ្វើការសិក្សាអំពីអត្រាសាយភាយកម្រិតជាតិដោយប្រើប្រាស់*វិធីសាស្ត្រសិក្សាបែបពហុប្រទេសរបស់អង្គការសុខភាពពិភពលោក (WHO)*។ វិធីសាស្ត្រនេះ ត្រូវបានជ្រើសរើសយកមកប្រើដោយសារវាត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ហើយត្រូវបានគេដឹងថាបានផ្តល់នូវទិន្នន័យគួរជាទីទុកចិត្ត ដែលអាចយកទៅប្រើប្រាស់សម្រាប់ការប្រៀបធៀបឆ្លងប្រទេស ហើយវាគោរពយ៉ាងខ្ជាប់ខ្ជួនតាមស្តង់ដារសីលធម៌ និងសុវត្ថិភាពដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

វត្ថុបំណងនៃការសិក្សា

វត្ថុបំណងនៃការសិក្សានេះគឺដើម្បី៖

ប៉ាន់ប្រមាណអត្រាសាយភាយ និងភាពញឹកញាប់ នៃអំពើហិង្សាលើស្ត្រី (VAW) ក្នុងទម្រង់ផ្សេងៗ៖ ផ្លូវកាយ ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ចលើស្ត្រី ដែលប្រព្រឹត្តិឡើងដោយដៃគូជិតស្និទ្ធ ក៏ដូចជាអំពើហិង្សាផ្លូវភេទ និងផ្លូវកាយ ដែលប្រព្រឹត្តិដោយជនល្មើសដទៃទៀតក្រៅពីដៃគូ (នៅក្នុងឯកសារនេះយើងក៏ហៅជនប្រភេទនេះថា “ជនមិនមែនជាដៃគូ” ផងដែរ) ចាប់តាំងពីអាយុ ១៥ ឆ្នាំ និងអំពើហិង្សាផ្លូវភេទមុនអាយុ ១៥ ឆ្នាំ។

កំណត់អំពីចំណងទាក់ទងរវាង អំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ជាមួយនឹងលទ្ធផលផ្នែកសុខភាព និងលទ្ធផលដទៃទៀតជាច្រើន។

កំណត់អំពីកត្តានានា ដែលអាចនឹងពាក់ព័ន្ធជាមួយការកាត់បន្ថយ (កត្តាការពារ) ឬបង្កើន (កត្តាហានិភ័យ) ហានិភ័យរបស់ស្ត្រីជាមួយនឹងអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ។

ចងក្រងជាឯកសារអំពីយុទ្ធសាស្ត្រ និងសេវានានាដែលស្ត្រីប្រើប្រាស់ដើម្បីទប់ទល់ជាមួយអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ។

បន្ថែមលើនេះទៀត
ការសិក្សានេះមានវត្ថុបំណងដើម្បី៖

បង្កើនសមត្ថភាព និងកិច្ចសហការថ្នាក់ជាតិ រវាងអ្នកស្រាវជ្រាវ និងអង្គការស្ត្រីនានាដែលធ្វើការលើការងារអំពើហិង្សាក្នុងគ្រួសារ។

បង្កើនការយល់ដឹង និងការយកចិត្តទុកដាក់ចំពោះអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និងអ្នកផ្តល់ការថែទាំសុខភាព។

ចូលរួមវិភាគទានក្នុងការអភិវឌ្ឍ បណ្តាញនៃអ្នកដែលប្តេជ្ញាចិត្តដើម្បីដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី។

វិធីសាស្ត្រ និងសំណាកគម្រូ

ការការសិក្សាស្រាវជ្រាវដោយផ្អែកលើមូលដ្ឋានគ្រួសារតាមបែបពហុវិស័យដោយផ្អែកតាមចំនួនប្រជាជន ត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៥។ ក្នុងគ្រួសារដែលត្រូវបានជ្រើសរើសនីមួយៗ មានតែស្ត្រី ដែលមានអាយុចន្លោះពី ១៥-៦៤ ឆ្នាំម្នាក់ប៉ុណ្ណោះដែលត្រូវបានជ្រើសរើសយកមកសម្ភាសន៍។ អ្នកសម្ភាសន៍ដែលទទួលបានការបណ្តុះបណ្តាល បញ្ចូលចម្លើយតបនឹងសំណួរទៅក្នុងកុំព្យូទ័រភ្លាមៗ។ វិធីនេះហៅថាការសម្ភាសន៍បុគ្គលដែលជួយសម្រួលដោយប្រើកុំព្យូទ័រ (Computer -Assisted Personal Interviewing) ឬ CAPI។ ការសិក្សាក្នុងប្រទេសកម្ពុជា ដើរតាមគោលការណ៍ណែនាំផ្នែកសីលធម៌ និងសុវត្ថិភាពរបស់អង្គការ WHO សម្រាប់ការស្រាវជ្រាវអំពីអំពើហិង្សាលើស្ត្រី ដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃការរក្សាការសម្ងាត់ និងឯកជនភាព ដើម្បីការពារសុវត្ថិភាពរបស់អ្នកតបសម្ភាសន៍ ព្រមទាំងមន្ត្រីសម្ភាសន៍ និងដើម្បីបង្កើនគុណភាពទិន្នន័យផង។ គណកម្មការដឹកនាំ និងក្រុមការងារបច្ចេកទេសមួយ ដែលរួមមានសមាសភាពដៃគូនៅក្នុងរដ្ឋាភិបាល រួមទាំងក្រសួងកិច្ចការនារីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ក្រោមការដឹកនាំរបស់អង្គការ UN Women អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍដទៃទៀត បានផ្តល់មគ្គុទ្ទេសក៍ស្តីពីការស្រាវជ្រាវ និងការប្រើប្រាស់ការស្រាវជ្រាវនេះ ដើម្បីផ្តល់ព័ត៌មានដល់គោលនយោបាយ និងកម្មវិធីនានា។ បទពិសោធរបស់ស្ត្រីជាមួយនឹងអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ និងជនដែលមិនមែនជាដៃគូ ត្រូវបានវាស់វែងដោយការសួរនូវសំណួរស្តី ពីអាកប្បកិរិយាជាក់លាក់ជាច្រើនទាក់ទងនឹងអំពើហិង្សាប្រភេទនីមួយៗ ដូចមានបង្ហាញជូនក្នុងប្រអប់លេខ ១។ ការសិក្សាផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើ “អំពើហិង្សាក្នុងគ្រួសារ” ដែលស្ត្រីបានជួបប្រទះ ដែលគេអាចហៅដោយឈ្មោះម៉្យាងទៀតថាអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ព្រោះគេបានឃើញថា នៅទូទាំងសាកលលោក អំពើហិង្សាលើស្ត្រីក្នុងទម្រង់នេះមានភាពសាយភាយជាងគេបំផុត។ រួមនៅក្នុងនេះមានទង្វើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលប្រព្រឹត្តិដោយដៃគូស្និទ្ធស្នាល បច្ចុប្បន្ន ឬអតីតដៃគូស្និទ្ធស្នាល (ប្តី/ដៃគូ) មិនថាជាដៃគូដែលបានរៀបការឬមិនបានរៀបការក្តី។ បន្ថែមលើនេះទៀត ការសិក្សាក៏បានពិនិត្យទៅលើអាកប្បកិរិយាត្រួតត្រា រួមទាំងទង្វើរឹតត្បិតបម្លាស់ទីរបស់ស្ត្រី ឬលទ្ធភាពរបស់ស្ត្រីក្នុងការទៅរកមិត្តភក្តិ និងសាច់ញាតិ និងការប្រជុំផងដែរ។ សម្រាប់

គោលបំណងនៃការវិភាគ សំណួរស្តីពីអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ត្រូវបានចែកទៅជាសំណួរដែលទាក់ទងនឹងអំពើហិង្សាកម្រិត “មធ្យម” និងអំពើហិង្សាដែលត្រូវបានចាត់ទុកថាជាអំពើហិង្សា “ធ្ងន់ធ្ងរ” ដោយក្នុងនោះ ការបែងចែករវាងភាពមធ្យម និងភាពធ្ងន់ធ្ងរ គឺផ្អែកលើលទ្ធភាពដែលទង្វើនោះទំនងជានឹងនាំឲ្យមានការរបួសផ្នែករាងកាយ ថ្វីបើព្រមពេលជាមួយគ្នានោះយើងទទួលស្គាល់ថារាល់អំពើហិង្សាទាំងអស់សុទ្ធតែអាចបង្កគ្រោះថ្នាក់បានក្តី។ សម្រាប់អំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តនីមួយៗដែលអ្នកតបសម្ភាស៍ រាយការណ៍ថាធ្លាប់បានកើតឡើងចំពោះរូបគាត់ គាត់នឹងត្រូវបានសួរថាតើអំពើនោះធ្លាប់បានកើតចំពោះរូបគាត់រហូត ឬក្នុងរយៈពេល ១២ខែ កន្លងទៅ និងតើកើតមានញឹកញាប់កម្រិតណា។ ការសិក្សាក៏បានដាក់បញ្ចូលនូវសំណួរស្តីពីស្ថានភាព ប្រជាសាស្ត្រសង្គមរបស់ស្ត្រី បទពិសោធទាក់ទងនឹងសុខភាព និងយុទ្ធសាស្ត្រក្នុងការស្វែងរកជំនួយ និងការដោះស្រាយរបស់គាត់ដើម្បីវាស់វែងនូវការយល់ដឹងកាន់តែទូលំទូលាយថែមទៀតអំពីកត្តាជាគន្លឹះនានាដែលពាក់ព័ន្ធនឹងបទពិសោធរបស់ស្ត្រីជាមួយអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ។

និយមន័យប្រតិបត្តិការនៃអំពើហិង្សា

ដែលត្រូវបានប្រើប្រាស់នៅក្នុងការ សិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពី
សុខភាព និងបទពិសោធក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា

អំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

- ត្រូវបានទះកំផ្លៀង ឬរងការចោលដោយអ្វីម៉្យាងដែលអាចធ្វើឲ្យគាត់ឈឺ
- ត្រូវបានច្រាន ឬព្រួញ ឬបោចសក់
- ត្រូវបានដាល់ដោយកណ្តាប់ដៃ ឬដោយអ្វីម៉្យាងដែលអាចធ្វើឲ្យគាត់ឈឺ
- ត្រូវបានទាត់ធាក់ ចាប់អូស ឬវាយដំ
- ត្រូវបានរឹតក ច្របាច់ក ឬដុតដោយចេតនា
- ជនល្មើសគម្រាមថានឹងប្រើប្រាស់ ឬបានប្រើជាក់ស្តែងនូវអាវុធប្រឆាំងនឹងគាត់

អំពើហិង្សាផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

- ត្រូវបានបង្ខំឲ្យរួមភេទពេលដែលនាងមិនចង់រួមភេទ ឧទាហរណ៍ ដោយការគម្រាម ឬជាក់សម្ពាធ
- ត្រូវបានបង្ខំឲ្យរួមភេទពេលដែលនាងមិនចង់រួមភេទដោយសារតែនាងខ្លាចអ្វីដែលដៃគូអាចនឹងធ្វើប្រសិនបើនាងបដិសេធ
- ត្រូវបានបង្ខំឲ្យធ្វើអ្វីផ្សេងទៀតក្នុងលក្ខណៈផ្លូវភេទដែលនាងមិនចង់ធ្វើ ឬដែលនាងយល់ថាជារឿងបន្ទាបបន្ថោក ឬធ្វើឲ្យអាម៉ាស់។

អំពើហិង្សាផ្លូវចិត្តប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

- ត្រូវបានប្រមាថ ឬធ្វើឲ្យមានអារម្មណ៍អាក្រក់អំពីខ្លួនឯង
- ត្រូវបានធ្វើឲ្យមានអារម្មណ៍តូចទាប ឬអាម៉ាស់នៅចំពោះមុខអ្នកដទៃ
- ជនល្មើសបានធ្វើទង្វើដើម្បីបន្លាច ឬបំភ័យនាងដោយចេតនា (ឧ. ដោយការស្រែកគំហក ឬវាយបំបែកវត្ថុអ្វីមួយ)
- ជនល្មើសគម្រាមជាពាក្យសំដីថានឹងធ្វើបាបនាង ឬនរណាម្នាក់ដែលនាងយកចិត្តទុកដាក់

អំពើហិង្សាផ្លូវសេដ្ឋកិច្ច

- ហាមឃាត់មិនឲ្យមានការងារធ្វើ មិនឲ្យទៅធ្វើការ មិនឲ្យលក់ដូរ មិនឲ្យរកប្រាក់ ឬចូលរួមក្នុងគម្រោងបង្កើតចំណូល
- ចំណូលដែលនាងរកបានត្រូវបានដកហូតយកពីនាងដោយផ្ទុយពីឆន្ទៈរបស់នាង
- ដៃគូបដិសេធមិនផ្តល់ប្រាក់ដែលនាងត្រូវការសម្រាប់ការចំណាយក្នុងគ្រួសារ សូម្បីតែគាត់មានប្រាក់សម្រាប់ទិញរបស់ផ្សេងទៀតក្តី (ដូចជាស្រា និងបារីជាដើម)

អំពើហិង្សាផ្លូវកាយក្នុងពេលមានផ្ទៃពោះ

- ត្រូវបានទះកំផ្លៀង វាយ ឬរងការវាយដំក្នុងពេលកំពុងមានផ្ទៃពោះ
- ត្រូវបានដាល់ ឬធាក់នៅត្រង់ពោះ ពេលកំពុងមានផ្ទៃពោះ

អាកប្បកិរិយាត្រួតត្រាធ្វើឡើងដោយដៃគូជិតស្និទ្ធ

- បុរសព្យាយាមរឹតត្បិតការទំនាក់ទំនងជាមួយគ្រួសារកំណើតរបស់នាង
- បុរសព្យាយាមរារាំងមិនឲ្យស្ត្រីជួបជាមួយមិត្តភក្តិ
- បុរសទាមទារចង់ដឹងថានាងនៅកន្លែងណាគ្រប់ពេលវេលា
- បុរសនោះខឹងប្រសិនបើនាងនិយាយជាមួយបុរសផ្សេង
- បុរសនោះតែងតែសង្ស័យថានាងមិនស្មោះត្រង់ជាមួយគាត់
- បុរសនោះរំពឹងថាឲ្យនាងសុំការអនុញ្ញាតិពីខ្លួនមុនពេលទៅកសេវាថែទាំសុខភាពសម្រាប់ខ្លួនឯង

អំពើហិង្សាផ្លូវកាយតាំងពីអាយុ ១៥ ឆ្នាំ ដោយមនុស្សដទៃ (ជនមិនមែនជាដៃគូ)

- តាំងពីអាយុ ១៥ ឆ្នាំមក មានមនុស្សណាម្នាក់

ក្រៅពីដៃគូរបស់នាង បានវាយដំ ឬធ្វើបាបផ្នែករាងកាយលើនាង

រងការរំលោភតាំងពី ១៥ ឆ្នាំ ដោយជនដែលមិនមែនជាដៃគូ

• ត្រូវបានបង្ខំដោយជនមិនមែនជាដៃគូ ឲ្យរួមភេទ នៅពេលដែលនាងមិនចង់ ឧទាហរណ៍ដោយការគម្រាមចំពោះនាងដាក់គំនាបលើនាង ឬដាក់នាងនៅក្នុងស្ថានភាពដែលនាងមិនអាចនិយាយថា «ទេ» បាន

អំពើហិង្សាផ្លូវភេទ (មិនមែនការរំលោភសេពសន្តវៈ) តាំងពីអាយុ ១៥ ឆ្នាំ ដោយជនមិនមែនជាដៃគូ

• ជនមិនមែនជាដៃគូណាម្នាក់បានព្យាយាមប៉ុន្តែ មិនបានសម្រេចក្នុងការបង្ខំនាងឲ្យរួមភេទ នៅពេលនាងមិនចង់ ឧទាហរណ៍ដូចជាតាមរយៈការគាបលើនាងឬដាក់នាងនៅក្នុងស្ថានភាពដែលមិនអាចឆ្លើយថា“ទេ” បាន។

• ប៉ះពាល់នាងក្នុងលក្ខណៈផ្លូវភេទផ្ទុយនឹងឆន្ទៈរបស់នាង។ ចំណុចនេះ រួមទាំង ឧទាហរណ៍ដូចជាការប៉ះពាល់ទ្រូង ឬផ្នែកអាថ៌កំបាំងនៃរាងកាយ។

• ឲ្យនាងប៉ះពាល់ផ្នែកអាថ៌កំបាំងនៃរាងកាយរបស់គេដោយផ្ទុយនឹងឆន្ទៈរបស់នាង។

ការរំលោភបំពានផ្លូវភេទក្នុងកុមារភាព

• មុនពេលអាយុ ១៥ ឆ្នាំ មាននរណាម្នាក់បានប៉ះពាល់នាងក្នុងលក្ខណៈផ្លូវភេទ ឬបង្ខំឲ្យនាងធ្វើអ្វីម៉្យាងក្នុងលក្ខណៈផ្លូវភេទ ដែលនាងមិនចង់ធ្វើ។

ស័ព្ទបច្ចេកទេសគន្លឹះ

ស្ត្រីធ្លាប់មានដៃគូ

និយមន័យនៃពាក្យ “ស្ត្រីធ្លាប់មានដៃគូ” គឺជាពាក្យសំខាន់បំផុតនៅក្នុងការសិក្សានេះ ព្រោះពាក្យនេះកំណត់និយមន័យប្រជាជនដែលអាចនឹងមានសក្តានុពលប្រឈមនឹងអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធហេតុនេះហើយទើបវាក្លាយជាភាគបែងសម្រាប់តួលេខអត្រាការសាយភាយ។ សម្រាប់គោលបំណងនៃការសិក្សានេះ ពាក្យដៃគូក្នុងន័យទូលាយត្រូវបានយកមកប្រើប្រាស់ ព្រោះរាល់ស្ត្រីដែលធ្លាប់មានទំនាក់ទំនងជាមួយដៃគូជិតស្និទ្ធ មិនថាពួកគេធ្លាប់បានរៀបការ ឬអត់ អាចនឹងប្រឈមនឹងហានីភ័យនៃអំពើហិង្សា។ ជាទូទៅ និយមន័យនៃពាក្យ “ស្ត្រីធ្លាប់មានដៃគូរ” រួមបញ្ចូលទាំងស្ត្រីដែលធ្លាប់រៀបការ ឬកំពុងស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬស្ថិតក្នុងទំនាក់ទំនង common-law។ ពាក្យនេះ ក៏គ្របដណ្តប់លើអ្នកកំពុងស្ថិតក្នុងទំនាក់ទំនងបែបការណាត់ជួបមើលចិត្តគ្នាផងដែរ។

អំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

អាកប្បកិរិយានៅក្នុងទំនាក់ទំនងជិតស្និទ្ធ ដែលបង្កឲ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត រួមទាំងទង្វើនៃការឈ្លានពានផ្លូវកាយ ការបង្ខំផ្លូវភេទ ការរំលោភបំពានផ្លូវចិត្ត និងអាកប្បកិរិយាត្រួតត្រា។ និយមន័យនេះ គ្របដណ្តប់លើអំពើហិង្សាដោយប្តី និងដៃគូរក្នុងពេលបច្ចុប្បន្នផង និងក្នុងពេលកន្លងមកផង។ ការសិក្សានេះ វាស់វែងលើអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច។

អំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទដែលប្រព្រឹត្តដោយដៃគូជិតស្និទ្ធ

ស្របពេលដែលការសិក្សានេះវាស់វែងនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ទិន្នន័យដែលត្រូវបានបង្ហាញអំពីផលវិបាក និងហានីភ័យ និងកត្តាការពារផ្តោតការយកចិត្តទុកដាក់លើបទពិសោធរបស់ស្ត្រីស្តីពីអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទដែលប្រព្រឹត្តិដោយដៃគូ ដែលសំដៅទៅលើស្ត្រីដែលធ្លាប់មានបទពិសោធចំពោះទង្វើយ៉ាងហោចណាស់មួយនៃអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ឬអំពើហិង្សាទាំងពីរទម្រង់នេះដែលប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ។

អំពើហិង្សាប្រព្រឹត្តិដោយជនមិនមែនជាដៃគូ

ការសិក្សាស្រាវជ្រាវនេះ ក៏ស្វែងយល់អំពីទំហំដែលស្ត្រីរាយការណ៍ថាមានបទពិសោធជួបអំពើហិង្សាដែលប្រព្រឹត្តិដោយជនល្មើសដែលមិនមែនជាបុរសដៃគូនាពេលបច្ចុប្បន្ន ឬកន្លងមក។ ចំណុចនេះរួមបញ្ចូលទាំងសំណួរស្តីពីអាកប្បកិរិយាដែលមានលក្ខណៈរំលោភបំពានផ្លូវកាយ ពីសំណាក់ជនល្មើសនោះ ចាប់តាំងពីអាយុ ១៥ ឆ្នាំមក នៅក្នុងបរិបទផ្សេងៗគ្នា (នៅសាលារៀន ឬកន្លែងធ្វើការ ពីសំណាក់មិត្តភក្តិ ឬអ្នកជិតខាង ឬនរណាម្នាក់ផ្សេងទៀត)។ សំណួរតាមដានបន្ត ស្វែងយល់អំពីភាពញឹកញាប់នៃអំពើហិង្សាសម្រាប់ជនល្មើសនីមួយៗ។

អត្រាសាយភាយ

អត្រាសាយភាយនៃ អំពើហិង្សាលើស្ត្រី សំដៅទៅលើសមមាត្រនៃស្ត្រី "ប្រឈមហានីភ័យ" នៅក្នុងចំណោមប្រជាជន ដែលធ្លាប់មានបទពិសោធជួបអំពើហិង្សា។ សម្រាប់អំពើហិង្សាប្រភេទមួយចំនួន ដូចជាអំពើហិង្សាផ្លូវភេទជាដើម ស្ត្រីទាំងអស់អាចនឹងត្រូវបានចាត់ទុកថា "ប្រឈមនឹងហានីភ័យ"។ សម្រាប់អំពើហិង្សាមួយចំនួនទៀត ដូចជា អំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ ជាដើម គឺមានតែស្ត្រីដែលមាន ឬធ្លាប់មានដៃគូជិតស្និទ្ធប៉ុណ្ណោះដែលត្រូវបានចាត់ទុកថាប្រឈមនឹងហានីភ័យ។

រយៈពេល ១២ ខែកន្លងទៅ (មុនពេលសម្ភាសន៍)

អត្រាសាយភាយរយៈពេល ១២ ខែ បង្ហាញសមមាត្រនៃស្ត្រីដែលធ្លាប់ជួបបទពិសោធន៍នូវទង្វើមួយ ឬច្រើននៃអំពើហិង្សាក្នុងរយៈពេល ១២ ខែកន្លងទៅ និងទង្វើហិង្សាដែលកើតមានកៀកនឹងពេលវេលានៃការវាស់វែង។ ចំណុចនេះ រួមទាំងអំពើហិង្សាដែលទើបចាប់ផ្តើម ក៏ដូចជាអំពើហិង្សាដែលអាចនឹងកើតមានតាំងពីប៉ុន្មានឆ្នាំកន្លងមកម្ល៉េះ។ អំពើហិង្សានោះអាចនឹងឈប់កើតមានទៀតហើយក្នុងរយៈពេល ១២ ខែកន្លងទៅ ឬនៅតែបន្តកើតឡើងនៅក្នុងពេលកំពុងវាស់វែង ឲ្យតែអំពើនោះបានកើតឡើងនៅក្នុងអំឡុងពេល ១២ ខែកន្លងទៅនេះ។

មួយជីវិត

អត្រាសាយភាយបង្ហាញយើងនូវសមមាត្រនៃស្ត្រីនៅក្នុងចំណោមប្រជាជនបច្ចុប្បន្នដែលធ្លាប់មានបទពិសោធន៍ជួបទង្វើមួយឬច្រើននៃអំពើហិង្សាក្នុងពេលណាមួយនៅក្នុងជីវិតរបស់ខ្លួន (ហេតុនេះ តាមនិយមន័យនេះ គឺត្រូវរួមបញ្ចូលទាំងស្ត្រីដែលត្រូវបានវាស់វែងសម្រាប់អត្រាសាយភាយក្នុងរយៈពេល ១២ ខែកន្លងទៅនេះផងដែរ។)

ដូចនៅក្នុងអត្រារយៈពេល ១២ ខែដែរ អត្រានេះមិនបានប្រាប់យើងថាតើអំពើហិង្សាដែលកើតឡើងនោះបានបន្តអស់រយៈពេលប៉ុន្មាន ឬញឹកញាប់ប៉ុណ្ណាឡើយ ដោយវាគ្រាន់តែប្រាប់យើងថាតើរឿងនេះធ្លាប់កើតមាន ឬអត់ប៉ុណ្ណោះ សូម្បីតែកើតតែមួយដងក៏ដោយ។ ជាទូទៅ ទំហំសំណាកសរុប ដែលសម្រេចបានគឺមានស្ត្រីចំនួន ៣៥៧៤ នាក់ ដែលមានអាយុចន្លោះ ១៥-៦៤ ឆ្នាំ ហើយក្នុងចំណោមនោះ មានស្ត្រីចំនួន ៣០៤៣ នាក់ដែលត្រូវបានកំណត់និយមន័យថាធ្លាប់មានដៃគូ (មិនថារៀបការ ឬមិនរៀបការក្តី)។ ៩៨% នៃស្ត្រីដែលត្រូវបានជ្រើសរើសមកសម្ភាសន៍ បានបំពេញកិច្ចសម្ភាសន៍ទាំងស្រុង។

៩៨% នៃស្ត្រីដែលត្រូវបានជ្រើសរើសមកសម្ភាសន៍ បានបំពេញកិច្ចសម្ភាសន៍ទាំងស្រុង។

ការពេញចិត្តរបស់អ្នកឆ្លើយតបជាមួយការសម្ភាសន៍



ជាទូទៅអ្នកឆ្លើយតបភាគច្រើនយល់ឃើញថាការចូលរួមនៅក្នុងការស្ទាបស្ទង់មតិនេះជាបទពិសោធវិជ្ជមាន និងបានបង្ហាញនូវការដឹងគុណដោយស្មោះស្ម័គ្រថាពួកគេអាចចែករំលែកបទពិសោធរបស់ខ្លួនជាមួយអ្នកដទៃដោយទំនុកចិត្តថា អ្វីៗដែលពួកគាត់និយាយ នឹងត្រូវរក្សាជាការសម្ងាត់។ នៅក្នុងឱកាសជាច្រើន អ្នកសម្ភាសន៍គឺជាមនុស្សតែម្នាក់គត់ដែលពួកគេធ្លាប់បានចែករំលែកព័ត៌មាននេះប្រាប់។

នៅពេលត្រូវបានសួរនៅចុងបញ្ចប់នៃការសម្ភាសន៍ថាតើពួកគាត់មានអារម្មណ៍ប្រសើរឡើង ឬ មិនមានអ្វីខុសគ្នា ឬមានអារម្មណ៍អាក្រក់ជាងមុន បន្ទាប់ពីការសម្ភាសន៍នេះ ភាគច្រើនលើលប់ពោលគឺ ៨0% នៃអ្នកឆ្លើយតប និយាយថាពួកគេមានអារម្មណ៍ប្រសើរជាងមុន។ អ្នកចូលរួមតិចជាងមួយភាគរយ បានរាយការណ៍ថា ពួកគាត់មានអារម្មណ៍មិនល្អ ឬអារម្មណ៍អាក្រក់ជាងមុនក្រោយការសម្ភាសន៍។

ចំណុចនេះ ជួយអះអាងបញ្ជាក់ថា ថ្វីបើអំពើហិង្សាក្នុងគ្រួសារ អាចនឹងត្រូវបានមនុស្សមួយចំនួនចាត់ទុកថាជារឿងឯកជនក្នុងគ្រួសារក្តី ប៉ុន្តែ ស្ត្រីចង់ និងបានទទួលអត្ថប្រយោជន៍ពីការចែករំលែកបទពិសោធរបស់ខ្លួន នៅពេលដែលពួកគេត្រូវបានសួរនៅក្នុងបរិយាកាសរក្សាការសម្ងាត់ និងនៅក្នុងលក្ខណៈប្រកបដោយការគោរព និងសប្បុរស។ ចំណុចនេះក៏ស៊ីសង្វាក់គ្នាជាមួយអ្វីដែល WHO បានរកឃើញនៅក្នុងប្រទេសផ្សេងៗភាគច្រើនផងដែរ។

" បន្ទាប់ពីការសម្ភាសន៍ អ្នកឆ្លើយតបបានថ្លែងអំណរគុណអ្នកសម្ភាសន៍ដល់ខ្ញុំជាច្រើនដង ពួកគាត់មានអារម្មណ៍ល្អ និងធូរស្រាល "។ -សម្តីរបស់អ្នកសម្ភាសន៍ម្នាក់

គំហើញសំខាន់ៗ

១/ អត្រាសាយភាយ និងទម្រង់នៃអំពើហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធក្នុងប្រភេទខុសៗគ្នា

២/ អត្រាសាយភាយ និងទម្រង់នៃអំពើហិង្សាផ្លូវកាយ និងផ្លូវភេទប្រព្រឹត្តដោយជនមិនមែនជាដៃគូ

៣/ ឥរិយាបទរបស់អ្នកឆ្លើយតបចំពោះអំពើហិង្សា

៤/ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទដែលប្រព្រឹត្ត ដោយដៃគូជិតស្និទ្ធមកលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ស្ត្រី

៥/ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ដែលប្រព្រឹត្តដោយដៃគូជិតស្និទ្ធមកលើសុខភាពបន្តពូជរបស់ស្ត្រី និងមកលើសុខមាលភាពរបស់កុមារ។

៦/ យុទ្ធសាស្ត្រក្នុងការទប់ទល់ និងការឆ្លើយតបរបស់ស្ត្រីចំពោះអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទដែលប្រព្រឹត្តដោយដៃគូជិតស្និទ្ធ។

៧/ កត្តាហានីភ័យ និងកត្តាការពារ ដែលពាក់ព័ន្ធនឹងបទពិសោធរបស់ស្ត្រីជាមួយអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទដែលប្រព្រឹត្តដោយដៃគូជិតស្និទ្ធ។

១/ ការសាយភាយនិងទម្រង់នៃអំពើហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធ

ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូ ដែលមានអាយុចន្លោះ ១៥ - ៦៤ ឆ្នាំ ធ្លាប់ជួបបទពិសោធនៃអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូជិតស្និទ្ធក្នុងជីវិតរបស់ពួកគេ

ក្នុងចំណោមស្ត្រីធ្លាប់មានដៃគូអាយុពី១៥ - ៦៤ ឆ្នាំ ១៥% បានរាយការណ៍ថាធ្លាប់បានជួបបទពិសោធអំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូជិតស្និទ្ធនៅក្នុងជីវិតរបស់ពួកគេ ហើយ ៥% ធ្លាប់បានជួបនៅក្នុងរយៈពេល ១២ ខែចុងក្រោយ។ ១០% បានរាយការណ៍ថាធ្លាប់រងអំពើហិង្សាផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធក្នុងជីវិតរបស់ខ្លួន និង ៤% ធ្លាប់បានជួបនៅក្នុងរយៈពេល ១២ ខែចុងក្រោយ។



រាយការណ៍ថាធ្លាប់បានជួបបទពិសោធអំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូជិតស្និទ្ធនៅក្នុងជីវិតរបស់ពួកគេ



នៅក្នុងរយៈពេល ១២ ខែចុងក្រោយ



រាយការណ៍ថាធ្លាប់រងអំពើហិង្សាផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធក្នុងជីវិតរបស់ខ្លួន



នៅក្នុងរយៈពេល ១២ ខែចុងក្រោយ

ជាទូទៅ អត្រាសាយភាយនៃអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធក្នុងមួយជីវិតស្ត្រីធ្លាប់មានដៃគូអាយុចន្លោះ ១៥ - ៦៤ ឆ្នាំគឺមានកម្រិត ២១% ហើយអត្រាការសាយភាយនាពេលបច្ចុប្បន្ន (ក្នុងអំឡុងពេល ១២ ខែចុងក្រោយ) ត្រូវបានរកឃើញថាមានកម្រិត ៨% (សូមមើលរូបភាពទី ២)។





ការសិក្សាក៏បានវាស់វែងលើអំពើហិង្សាផ្លូវចិត្ត និងបានរកឃើញថា ៣២% នៃស្ត្រីធ្លាប់មានដៃគូធ្លាប់មានបទពិសោធជួបអំពើហិង្សាផ្លូវចិត្តពីដៃគូ យ៉ាងហោចណាស់ម្តងក្នុងជីវិតរបស់ខ្លួន។



រូបភាពទី ២៖

ភាគរយនៃស្ត្រីធ្លាប់មានដៃគូអាយុ ១៥ - ៦៤ ឆ្នាំ ដែលបានរាយការណ៍អំពីប្រភេទផ្សេងៗនៃអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធទៅតាមអំឡុងពេល



បទពិសោធរបស់ស្ត្រីជាមួយអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធមានភាពញឹកញាប់ ហើយស្ត្រីភាគច្រើនបានរាយការណ៍អំពីអំពើហិង្សាក្នុងទម្រង់ធ្ងន់ធ្ងរ

ក្នុងចំណោមស្ត្រីដែលបានរាយការណ៍អំពីបទពិសោធអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ មានស្ត្រីបីភាគបួន ដែលធ្លាប់មានបទពិសោធជួបអំពើហិង្សាក្នុងទម្រង់ធ្ងន់ធ្ងរ (សូមមើលរូបភាពទី ៣)។ បន្ថែមលើនេះទៀត សម្រាប់អំពើហិង្សាគ្រប់ទម្រង់ទាំងអស់ ការសិក្សាបានរកឃើញថា ស្ត្រីច្រើនតែជួបនូវទង្វើហិង្សាញឹកញាប់ ជាជាងព្រឹត្តិការណ៍ដែលកើតតែម្តងរួចហើយឈប់កើត។

បន្ថែមលើនេះទៀត សម្រាប់អំពើហិង្សាគ្រប់ទម្រង់ទាំងអស់ ការសិក្សាបានរកឃើញថា ស្ត្រីច្រើនតែជួបនូវទង្វើហិង្សាញឹកញាប់ ជាជាងជាព្រឹត្តិការណ៍ដែលកើតតែម្តងរួចឈប់កើត។

រូបភាពទី ៣៖

សមមាត្រនៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ប្រព្រឹត្តិ ដោយដៃគូ ដែលបានរាយការណ៍អំពីទង្វើក្នុងកម្រិតមធ្យម និងទង្វើកម្រិតធ្ងន់ធ្ងរ



មានការកើតឡើងរួមគ្នារវាងទម្រង់ផ្សេងៗនៃអំពើហិង្សាប្រព្រឹត្តិដោយដៃគូ ដែលស្ត្រីធ្លាប់ជួបប្រទះ

ការសិក្សារកឃើញថាជារឿយៗ ដៃគូដែលប្រើហិង្សា តែងប្រើអំពើហិង្សាជាច្រើនប្រភេទ ដូចអ្វីដែលយើងបានពិភាក្សាខាងដើមហើយថា ព្រឹត្តិការណ៍ហិង្សាមិនមែនកើតឡើងជាករណីហិង្សាដាច់ដោយឡែកនោះឡើយ ប៉ុន្តែ ច្រើនតែតំណាងឲ្យទម្រង់នៃការរំលោភបំពានដែលបន្តទៅមុខ។ ស្ត្រីភាគច្រើននៅក្នុងការសិក្សាស្រាវជ្រាវធ្លាប់ទទួលរងអំពើហិង្សាផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ ដែលប្រព្រឹត្តិដោយដៃគូជិតស្និទ្ធក្នុងពេលតែមួយ ឬអំពើហិង្សា

ផ្លូវចិត្ត និងផ្លូវកាយ។ ស្ត្រីមួយភាគតូចបានរាយការណ៍ថាធ្លាប់ជួបអំពើហិង្សាផ្លូវភេទដោយមិនមានអំពើហិង្សាផ្លូវកាយ។ ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីបីនាក់ ត្រូវបានរកឃើញថា ធ្លាប់បានជួបយ៉ាងហោចណាស់មួយទម្រង់នៃឥរិយាបថត្រួតត្រាពីដៃគូ។

ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីបីនាក់ ត្រូវបានរកឃើញថា ធ្លាប់បានជួបយ៉ាងហោចណាស់មួយនៃអាកប្បកិរិយាត្រួតត្រាពីដៃគូ។

ស្ត្រីក្មេងដែលរៀបការហើយប្រឈមហានិភ័យកាន់តែខ្ពស់ នៃការជួបនឹងអំពើហិង្សានាពេលបច្ចុប្បន្នប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

នៅពេលដែលយើងពិនិត្យមើល អំពើហិង្សានាពេលបច្ចុប្បន្ន (អំពើហិង្សាក្នុងរយៈពេល ១២ ខែកន្លងមក) ក្នុងចំណោមស្ត្រីដែលធ្លាប់មានដៃគូ ការសិក្សារកឃើញថា ក្នុងចំណោមក្រុមអាយុដំបូងបំផុត អំពើហិង្សានាពេលបច្ចុប្បន្នមានកម្រិតខ្ពស់ ដូចនេះ អំពើហិង្សាចាប់ផ្តើមតាំងពីដើមដំបូងនៃទំនាក់ទំនង (រូបភាពទី ៤)។ បើពិនិត្យទៅលើទិន្នន័យបច្ចុប្បន្ន និងទិន្នន័យពេញមួយជីវិតរួមគ្នា បានបង្ហាញថា សមាមាត្រនៃពេលបច្ចុប្បន្ន លើមួយជីវិតមានកម្រិតខ្ពស់បំផុតក្នុងចំណោមអ្នកដែលមានអាយុចន្លោះពី ១៥-២៤ ឆ្នាំ រួចហើយមានកម្រិតថយចុះ ដោយបង្ហាញថា អំពើហិង្សាថយចុះពេលមានអាយុកាន់តែច្រើន។

បើពិនិត្យលើស្ត្រីអាយុ ១៥-៤៩ ឆ្នាំ សម្រាប់ការប្រៀបធៀបជាមួយការសិក្សាដទៃទៀត រួមទាំងការអង្កេតប្រជាសាស្ត្រ សុខភាពកម្ពុជាផងនោះ ការសិក្សានេះបង្ហាញថា អត្រាការសាយភាយអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ មានអត្រា ២១% ហើយអត្រាសាយភាយបច្ចុប្បន្នមានកម្រិត ៩% (សូមមើលរូបភាពទី ៤)។ អត្រាអំពើហិង្សានាពេលបច្ចុប្បន្នមានកម្រិតខ្ពស់ជាងកម្រិតអាយុ ១៥-៦៤ ឆ្នាំបន្តិច អាស្រ័យដោយមានហានិភ័យនៃអំពើហិង្សាកើនឡើងក្នុងចំណោមក្រុមអាយុវ័យក្មេង។



រូបភាពទី ៤៖

អត្រាសាយភាយនៃ IPV ផ្លូវកាយ និង/ឬផ្លូវភេទ ក្នុងចំណោមស្ត្រីដែលធ្លាប់មានដៃគូ ចែកទៅតាមកម្រិតអាយុ

២/ អត្រាសាយភាយ និងទម្រង់អំពើហិង្សាប្រព្រឹត្តដោយជនមិនមែនជាដៃគូ

ស្ត្រីក៏មានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តដោយជនមិនមែនជាដៃគូផងដែរ ប៉ុន្តែ អំពើហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធគឺជាទម្រង់អំពើហិង្សាប្រឆាំងស្ត្រីដែលគេឃើញកើតមានច្រើនជាងគេបំផុត

ការសិក្សារកឃើញថា ១៤% នៃស្ត្រីទាំងអស់ដែលមានអាយុ១៥-៦៤ឆ្នាំ ធ្លាប់ទទួលរងអំពើហិង្សាដែលប្រព្រឹត្តដោយជនមិនមែនជាដៃគូនៅក្នុងមួយជីវិតរបស់ពួកគេ។ ៤% នៃស្ត្រីអាយុចាប់ពី ១៥-៦៤ ឆ្នាំបានរាយការណ៍ថាធ្លាប់ជួបអំពើហិង្សាផ្លូវភេទប្រព្រឹត្តដោយជនមិនមែនជាដៃគូ ក្រោយពេលអាយុ ១៥ ឆ្នាំ ហើយ ២% បានរាយការណ៍ថាធ្លាប់រងអំពើហិង្សាផ្លូវភេទដោយជនមិនមែនជាដៃគូ មុនពេលអាយុ ១៥ ឆ្នាំ (ការរំលោភបំពានផ្លូវភេទក្នុងកុមារភាព)។ ដោយឡែក ការរាយការណ៍អំពីការរំលោភបំពានផ្លូវភេទក្នុងកុមារភាពដែលបានរកឃើញ ការប៉ាន់ប្រមាណដែលទាបជាងចំនួនជាក់ស្តែង ពីព្រោះ ភាពអាម៉ាស់ទាក់ទងនឹងទម្រង់នៃអំពើហិង្សាប្រភេទនេះនៅមានកម្រិតខ្ពស់។

ជនល្មើសនៃអំពើហិង្សាផ្លូវកាយ ដោយជនមិនមែនជាដៃគូភាគច្រើនត្រូវបានស្គាល់ដោយជនរងគ្រោះ

តាមធម្មតា ជនរងគ្រោះច្រើនតែស្គាល់ជនល្មើសនៃអំពើហិង្សាប្រព្រឹត្តិដោយជនមិនមែនជាដៃគូ។ ឪពុកម្តាយ បងប្អូនបង្កើត និងមិត្តភក្តិ ត្រូវបានកំណត់ថាជាជនល្មើសនៃករណីភាគច្រើនបំផុតរបស់អំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយជនមិនមែនជាដៃគូ រីឯជនមិនដែលស្គាល់អ្នកធ្វើការជាមួយ និងមិត្តភក្តិត្រូវបានកំណត់ថាជាជនល្មើសនៃករណីភាគច្រើនបំផុតរបស់អំពើហិង្សាផ្លូវភេទប្រព្រឹត្តិដោយជនមិនមែនជាដៃគូក្រោយអាយុ ១៥ ឆ្នាំ។ មិត្តភក្តិ និងអ្នកធ្លាប់ស្គាល់ រួមគ្នាជាមួយសមាជិកដទៃទៀតក្នុងគ្រួសារ ត្រូវបានអ្នកឆ្លើយតបរាយការណ៍ថាជាជនល្មើសក្នុងករណីភាគច្រើនបំផុតនៃការរំលោភបំពានផ្លូវភេទក្នុងកុមារភាព។

មួយភាគប្រាំនៃស្ត្រី បានរាយការណ៍ថាបទពិសោធការរួមភេទដំបូងរបស់ខ្លួន ជាការរួមភេទក្រោមការដាក់សម្ពាធឬដោយបង្ខំ

ភាគច្រើននៃស្ត្រីនៅក្នុងការសិក្សាស្រាវជ្រាវ បានរាយការណ៍ថា បទពិសោធនៃការរួមភេទលើកដំបូងរបស់ពួកគេគឺជាអ្វីដែលពួកគេចង់ឲ្យកើតមានឡើង។ ប៉ុន្តែ ២០% នៃស្ត្រីបានរាយការណ៍ថា បទពិសោធការរួមភេទលើកដំបូងរបស់ពួកគេស្ថិតក្រោមការដាក់សម្ពាធ(ភាគច្រើន)ឬដោយបង្ខំ(សូមមើលរូបភាពទី៥)

មានការលេចឡើងនូវទម្រង់ថ្មីៗនៃការបៀតបៀនផ្លូវភេទ

ប្រាំភាគរយនៃស្ត្រី បានរាយការណ៍ថាធ្លាប់មានបទពិសោធជួបនូវការបៀតបៀនផ្លូវភេទក្នុងទម្រង់ណាមួយក្នុងជីវិតរបស់ខ្លួន ដែលរួមមានទាំងការបៀតបៀនផ្លូវភេទក្នុងកន្លែងធ្វើការផងដែរ។ ការបៀតបៀនផ្លូវភេទក្នុងទម្រង់ដែលគេ ឃើញច្រើនបំផុតគឺតាមរយៈមធ្យោបាយអេឡិចត្រូនិច ដែលជាការឆ្លុះបញ្ចាំងឲ្យឃើញនូវទម្រង់ថ្មីៗនៃការបៀតបៀន ដែលពាក់ព័ន្ធនឹងការកើនឡើងនៃលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា។

រូបភាពទី ៥៖

ភាគរយនៃស្ត្រីដែលបានរាយការណ៍ថារងការបង្ខំនៅក្នុងបទពិសោធការរួមភេទលើកដំបូងរបស់ខ្លួន (ក្នុងចំណោមស្ត្រីដែលធ្លាប់រួមភេទ)





រាយការណ៍ថាធ្លាប់មានបទពិសោធន៍ជួបនូវការបៀតបៀនផ្លូវភេទក្នុងទម្រង់ណាមួយក្នុងជីវិតរបស់ខ្លួន

៣/ ឥរិយាបថចំពោះអំពើហិង្សា

មានការអត់ទ្រាំ និងការទទួលយកកម្រិតខ្ពស់ចំពោះការប្រើប្រាស់អំពើហិង្សាលើស្ត្រី



ស្ទើរតែពាក់កណ្តាលនៃស្ត្រី (៤៩%) ក្នុងការសិក្សានេះ យល់ស្របថា នៅក្រោមកាលៈទេសៈមួយចំនួន ប្តីមានហេតុផលគ្រប់គ្រាន់ដើម្បីវាយប្រពន្ធរបស់ខ្លួន។ ហេតុផលនៃការប្រើហិង្សាដែលអ្នក តបសម្ភាសន៍ភាគច្រើនយល់ស្របជាមួយគឺភាពមិនស្មោះត្រង់របស់ប្រពន្ធ (៣៧% នៃស្ត្រីទាំងអស់) និងការមិនមើលថែកូនបានត្រឹមត្រូវ (៣៥% នៃស្ត្រីទាំងអស់)។ ស្ត្រីដែលធ្លាប់រងការរំលោភបំពាន ច្រើនតែយល់ស្របជាមួយ ហេតុផលសម្រាប់ការប្រើហិង្សាច្រើនជាងស្ត្រីដែលមិនធ្លាប់ជួបអំពើហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធ។

ស្ត្រីភាគច្រើនយល់ស្របថា វាជារឿង "អាចទទួលយកបាន" សម្រាប់ប្រពន្ធក្នុងការបដិសេធមិនព្រមរួមភេទក្នុងកាលៈទេសៈមួយចំនួន ប៉ុន្តែ ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់មានអារម្មណ៍ថា ប្រពន្ធមិនអាចបដិសេធមិនព្រមរួមភេទមិនថាក្នុងកាលៈទេសៈណាឡើយ។

ទស្សនៈរបស់ស្ត្រីស្តីពីថាតើពេលណាដែលជារឿង "អាចទទួលយកបាន" សម្រាប់ប្រពន្ធក្នុងការបដិសេធមិនព្រមរួមភេទជាមួយប្តីរបស់ខ្លួន ឆ្លុះបញ្ចាំងឲ្យឃើញនូវជំនឿបែបប្រពៃណី អំពីតួនាទីរបស់ប្រពន្ធនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍។ ស្ត្រីភាគច្រើនយល់ថាវាជារឿង "អាចទទួលយកបាន" សម្រាប់ប្រពន្ធក្នុងការបដិសេធមិនព្រមរួមភេទក្នុងកាលៈទេសៈមួយចំនួនដោយក្នុងនោះមូលដ្ឋានភាគច្រើនបំផុតដែលគេគិតថាអាចទទួលយកបាននោះ

គឺក្នុងករណីដែលប្រពន្ធឈឺ ឬក្នុងករណីដែលប្តីស្រវឹងស្រា។ ប៉ុន្តែ ស្ត្រីក្នុងចំនួនតិចតួចបំផុត ដែលយល់ស្របថា ប្រពន្ធអាចបដិសេធមិនព្រមរួមភេទ ដោយសារតែនាងមិនចង់រួមភេទ។ ជារួម ប្រមាណមួយភាគប្រាំនៃស្ត្រីមានអារម្មណ៍ថា វាជារឿងមិនអាចទទួលយកបានទេក្នុងការបដិសេធការរួមភេទ មិនថាក្នុងកាលៈទេសៈណាក្តី ដែលត្រូវបានបង្ហាញនៅក្នុងការសិក្សានេះ។

៤/ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទប្រព្រឹត្តដោយដៃគូមកលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ស្ត្រី

ស្ត្រីដែលមានបទពិសោធធ្លាប់ជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ប្រព្រឹត្តដោយដៃគូ បន្តមានរបួសស្នាមផ្សេងៗជាច្រើនប្រភេទ ប៉ុន្តែ ពួកគេកម្រស្វែងរកការព្យាបាលវេជ្ជសាស្ត្រ

៦៦%

នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូបានរាយការណ៍ថាអំពីហិង្សាបានប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ពួកគេយ៉ាងខ្លាំង។

រូបភាពទី ៦៖

សមមាត្រនៃស្ត្រីដែលបានទទួលការថែទាំសុខភាពក្នុងចំណោមស្ត្រីដែលត្រូវការការព្យាបាលអាស្រ័យដោយមានរបួសបង្កឡើងដោយអំពើហិង្សាពីដៃគូ



ស្ត្រីជាច្រើនដែលធ្លាប់មានដៃគូ ដែលធ្លាប់មានបទពិសោធជួបអំពើហិង្សាដោយដៃគូជិតស្និទ្ធ ផ្លូវកាយ និង/ឬផ្លូវភេទ ចាត់ទុកថាអំពើហិង្សាប៉ះពាល់លើសុខភាព និងសមត្ថភាពរបស់ពួកគេក្នុងការបំពេញមុខងារជាធម្មតា។ ពីរភាគបី (៦៦%) នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូបានរាយការណ៍ថាអំពើហិង្សាបានប៉ះពាល់ដល់សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ពួកគេយ៉ាងខ្លាំង។ ២៥% នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូបានរាយការណ៍ថាធ្លាប់រងរបួសយ៉ាងហោចណាស់ម្តងក្នុងមួយជីវិតរបស់ខ្លួន។ ពួកគេបានរាយការណ៍អំពីរបួសផ្សេងៗជាច្រើន ដែលមានចាប់តាំងស្នាមជាំ ដាច់រលាត់ទៅដល់បាក់ធ្មេញ និងរបួសខាងក្នុង។ ថ្វីបើ ៩០% នៃស្ត្រីដែលធ្លាប់រងរបួសបានរាយការណ៍ថាខ្លួនរងរបួសធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីទៅរកការថែទាំវេជ្ជសាស្ត្រក្តី ប៉ុន្តែ ជិត ៤៧% នៃស្ត្រីទាំងនោះ មិនដែលទៅរកការព្យាបាលឡើយ (សូមមើលរូបភាពទី ៦)។

គំហើញ៖ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយនិង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ច្រើនតែរាយការណ៍ថាមានការឈឺចាប់ មិនស្រួលខ្លួន និងបញ្ហាការចងចាំ ឬការប្រមូលអារម្មណ៍ ក្នុងលក្ខណៈគួរឲ្យកត់សម្គាល់ ក្នុងរយៈពេល ៤ សប្តាហ៍កន្លងទៅ

បន្ទាប់ពីសម្រួលយោងទៅតាមអាយុ និងការអប់រំរួចមក ការសិក្សាបានបង្ហាញនូវចំណងទាក់ទងដ៏គួរឲ្យកត់សម្គាល់ផ្នែកស្ថិតិរវាងបទពិសោធស្ត្រីដែលជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ជាមួយនឹងបទពិសោធដែលគាត់មានការឈឺចាប់ មិនស្រួលខ្លួន បញ្ហាជាមួយការចងចាំ ឬការប្រមូលអារម្មណ៍ និងជួបបញ្ហាសុខភាពណាមួយដែលត្រូវបានសាកសួរ នៅក្នុងរយៈពេល ៤ សប្តាហ៍កន្លងមក។ ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ រាយការណ៍ថាស្ថានភាពសុខភាពជាទូទៅរបស់ពួកគាត់ខ្សោយ ឬខ្សោយខ្លាំងជាងស្ត្រីដែលមិនធ្លាប់មានបទពិសោធន៍ជួបអំពើហិង្សា ប៉ុន្តែ ចំណងទាក់ទងនេះបាត់បង់នូវភាពគួរឲ្យកត់សម្គាល់ក្រោយពីបានសម្រួលយោងទៅតាមអាយុ និងការអប់រំ។

ស្ត្រីដែលមានបទពិសោធន៍ជួបអំពើហិង្សា ក៏ច្រើនតែរាយការណ៍អំពីការដក់បារីនាពេលបច្ចុប្បន្ន និងការបរិភោគគ្រឿងស្រវឹងជាញឹកញាក់ ក្នុងលក្ខណៈគួរឲ្យកត់សម្គាល់ផងដែរ។ ចំណុចនេះគឺស៊ីសង្វាក់គ្នាជាមួយភស្តុតាងដទៃទៀត ដែលបង្ហាញថាផលប៉ះពាល់នៃអំពើហិង្សាគឺមានហួសឆ្ងាយពីរបួសដោយផ្ទាល់ដែលបង្កឡើងដោយអំពើហិង្សា ហើយមានផលវិបាកដោយប្រយោលរយៈពេលវែងយ៉ាងទូលំទូលាយផងដែរ។

បទពិសោធអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូជិតស្និទ្ធដែលស្ត្រីបានជួបប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពផ្លូវចិត្តរបស់ពួកគេ

ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ត្រូវបានរកឃើញថា ច្រើនតែរងនូវបញ្ហាសំពាធផ្លូវចិត្តកម្រិតខ្ពស់គួរឲ្យកត់សម្គាល់បើប្រៀបធៀបជាមួយស្ត្រីដែលមិនធ្លាប់មានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូ។ បន្ថែមលើនេះទៀត ស្ត្រីដែលធ្លាប់មានបទពិសោធ ធ្លាប់ទទួលរងអំពើហិង្សាដោយដៃគូជិតស្និទ្ធ ច្រើនតែមានគំនិតចង់សម្លាប់ខ្លួនក្នុងកម្រិតគួរឲ្យកត់សម្គាល់ ហើយច្រើនតែបានប៉ុនប៉ងសម្លាប់ខ្លួនបើប្រៀបធៀបជាមួយស្ត្រីដែលមិនធ្លាប់មានបទពិសោធ ធ្លាប់ទទួលរងអំពើហិង្សាដោយដៃគូជិតស្និទ្ធ (រូបភាពទី ៧)។ ចំណុចនេះ គួសបញ្ជាក់ឲ្យឃើញនូវផលវិបាកយ៉ាងធ្ងន់ធ្ងរនៃអំពើហិង្សាដោយដៃគូជិតស្និទ្ធ ក៏ដូចជាតម្រូវការឲ្យមាននូវសេវាសុខភាពផ្លូវចិត្តកាន់តែទូលំទូលាយជាងនេះថែមទៀត។

<u>រូបភាពទី ៧៖</u>

ភាគរយនៃស្ត្រីដែលបានរាយការណ៍ថាមានគំនិតចង់សម្លាប់ខ្លួន និងបានប៉ុនប៉ងសម្លាប់ខ្លួន យោងទៅតាមបទពិសោធរបស់ពួកគេជាមួយអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ*



*ចំណងទាក់ទងរវាងបទពិសោធអំពើហិង្សាដោយដៃគូជិតស្និទ្ធជាមួយនឹងគំនិតចង់សម្លាប់ខ្លួន និងការប៉ុនប៉ងចង់សម្លាប់ខ្លួនដែលត្រូវបានរកឃើញថាមានភាពគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិ

៥/ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូមកលើសុខភាពបន្តពូជ និងសុខមាលភាពរបស់កុមារ

កូនរបស់ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយនិង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ច្រើនតែមានបញ្ហាខាងផ្លូវចិត្ត និងអាកប្បកិរិយា/ឥរិយាបថ

ប្រមាណ ៧០% នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូ បានរាយការណ៍ថា កូនៗរបស់ពួកគេមានវត្តមានក្នុងអំឡុងពេលករណីអំពើហិង្សាកើតឡើង

ប្រមាណ ៧០% នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូ បានរាយការណ៍ថា កូនៗរបស់ពួកគេមានវត្តមានក្នុងអំឡុងពេលករណីអំពើហិង្សាកើតឡើង (សូមមើលរូបភាពទី ៨)។ ក្នុងចំណោមស្ត្រីដែលបានរាយការណ៍ថាធ្លាប់មានបទពិសោធធ្លាប់ទទួលរងអំពើហិង្សាដោយដៃគូជិតស្និទ្ធ និងមានកូនម្នាក់ឬច្រើននាក់ដែលមានអាយុចន្លោះ ៦-១២ ឆ្នាំ រស់នៅក្នុងផ្ទះ ស្ត្រីចំនួន ១៥% បានរាយការណ៍ថាកូនរបស់ខ្លួនមានបញ្ហាផ្លូវចិត្ត ឬបញ្ហាអាកប្បកិរិយាមួយចំនួន (ការយល់សប្តិអាក្រក់ញឹកញាប់ នោមដាក់កន្ទេលញឹកញាប់ មានចរិតទុយមុយ ឬឯកាពីសង្គម ឬមាន ចរិតច្រងេងច្រងាង) បើប្រៀបធៀបនឹងចំនួន ១១% នៃស្ត្រីមិនរងការរំលោភបំពាន។ ជាងនេះទៀត ពីរដង (ទំនាក់ទំនងដែលមានភាពគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិ) នៃកុមារដែលរស់នៅក្នុងផ្ទះមានអំពើហិង្សា ច្រើនតែរៀនធ្លាក់ ឬរៀនត្រួតថ្នាក់ និងឈប់រៀន ឬបោះបង់ការសិក្សា។

រូបភាពទី ៨៖

ភាពញឹកញាប់នៃវត្តមានរបស់កុមារក្នុងពេលមានអំពើហិង្សាកើតឡើង ក្នុងចំណោមស្ត្រីដែលធ្លាប់មានបទពិសោធជួបអំពើហិង្សាផ្លូវកាយប្រព្រឹត្តិដោយដៃគូ



ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ មានហានីភ័យខ្ពស់ចំពោះការរំលូត និងការរលូតកូនក្នុងកម្រិតគួរឲ្យកត់សម្គាល់

៤% នៃស្ត្រីដែលធ្លាប់មានផ្ទៃពោះបានរាយការណ៍ថាគាត់ធ្លាប់រងការរំលោភបំពានផ្លូវកាយ ក្នុងអំឡុងពេលមានផ្ទៃពោះយ៉ាងហោចណាស់ម្តង។ ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយនិង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ច្រើនតែរាយការណ៍អំពីករណីរលូត និងរំលូតកូនក្នុងកម្រិតគួរឲ្យកត់សម្គាល់ (រូបភាពទី ៩)។ ទំនាក់ទំនងជាមួយករណីកូនស្លាប់ក្នុងពោះ មិនត្រូវបានរកឃើញថាមានភាពគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិទេ។ បន្ថែមលើសនេះទៀត លទ្ធផលបានបង្ហាញថា ស្ត្រីដែលមានបទពិសោធន៍ជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ បច្ចុប្បន្នច្រើនតែមិនសូវប្រើមធ្យោបាយការពារកំណើត ដូចស្ត្រីដែលមិនធ្លាប់មានបទពិសោធន៍ជួបអំពើហិង្សា (ថ្វីបើចំណុចនេះមិនមានភាពគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិក្តី) ហើយដែលចំណុចនេះ អាចឆ្លុះបញ្ចាំងឲ្យឃើញថា ស្ត្រីដែលមានបទពិសោធន៍ជួបអំពើហិង្សា មានលទ្ធភាពគ្រប់គ្រងកម្រិតទាប លើជម្រើសក្នុងបញ្ហាសុខភាពបន្តពូជ។

« គាត់វាយខ្ញុំរហូតដល់រលូតកូនក្នុងផ្ទៃដែលមានអាយុ ៦ ខែ។ គាត់វាយពោះខ្ញុំ ពីរថ្ងៃក្រោយខ្ញុំឈឺពោះ ហើយកូនក៏រលូតតែម្តង។ ខ្ញុំមិននឹកស្មានថា ខ្ញុំនៅមានជីវិតនោះទេ។ »

- សម្តីរបស់ស្ត្រីម្នាក់នៅខេត្តកំពង់ធំ

<u>រូបភាពទី ៩៖</u>

ភាគរយនៃស្ត្រីធ្លាប់មានផ្ទៃពោះ ដែលបានរាយការណ៍ថាធ្លាប់មានការរលូតកូន ការរំលូតកូន ឬកូនស្លាប់ក្នុងពោះ ដោយយោងទៅតាមបទពិសោធរបស់ពួកគេជាមួយអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ



*ទំនាក់ទំនងរវាងបទពិសោធ នៃអំពើហិង្សាដោយដៃគូជិតស្និទ្ធ ជាមួយការរលូតកូន និងការរំលូតកូន ត្រូវបានរកឃើញថាមានលក្ខណៈគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិ

ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ ច្រើនតែមានផ្ទៃពោះដោយមិនបានព្រាងទុក

ការសិក្សាបានរកឃើញថា ស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ បានរាយការណ៍ក្នុងកម្រិតគួរឲ្យកត់សម្គាល់ថា ការមានផ្ទៃពោះលើកចុងក្រោយរបស់ពួកគេ គឺកើតមានឡើងដោយមិនបានព្រាងទុក ហើយច្រើនតែបានបរិភោគគ្រឿងស្រវឹងនៅក្នុងពេលមានផ្ទៃពោះលើកចុងក្រោយរបស់ខ្លួន បើប្រៀបធៀបជាមួយស្ត្រីដែលរាយការណ៍ថាខ្លួនមិនធ្លាប់មានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូ។ ចំណុចនេះបញ្ជាក់ឲ្យឃើញថា បទពិសោធជាមួយអំពើហិង្សាគឺមានទំនាក់ទំនងជាមួយអាកប្បកិរិយាគ្រោះថ្នាក់ដែលមានសក្តានុពលអាចបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានចំពោះលទ្ធផលនៃការមានផ្ទៃពោះ។

មានភាគរយខ្ពស់ នៃស្ត្រីដែលរងការរំលោភបំពាន បានរាយការណ៍ថា ពួកគាត់មិនបានទទួលការពិនិត្យផ្ទៃពោះ និងការថែទាំក្រោយសម្រាល ក្នុងអំឡុងពេលមានផ្ទៃពោះលើកចុងក្រោយរបស់ខ្លួន ប៉ុន្តែ ទំនាក់ទំនងនេះមិនត្រូវបានរកឃើញថាមានភាពគួរឲ្យកត់សម្គាល់ផ្នែកស្ថិតិឡើយ។ ជាទូទៅ សមាមាត្រដ៏ខ្ពស់ចំពោះស្ត្រីក្នុងប្រទេសកម្ពុជាបានទទួលការពិនិត្យផ្ទៃពោះ ថ្វីបើស្ត្រីក្នុងចំនួនតែពាក់កណ្តាលប៉ុណ្ណោះដែលបានរាយការណ៍ថាបានទទួលការថែទាំក្រោយពេលសម្រាល។

អំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូជិតស្និទ្ធ ជះឥទ្ធិពលដោយផ្ទាល់លើផលិតភាពរបស់ស្ត្រី

ផលវិបាកផ្នែកសុខភាពផ្លូវកាយ ផ្លូវចិត្ត និងសុខភាពបន្តពូជដែលបណ្តាលមកពីអំពើហិង្សា គឺជះឥទ្ធិពលជាអវិជ្ជមានចំពោះផលិតភាពរបស់ស្ត្រី។

មួយភាគបីនៃស្ត្រីធ្លាប់មានដៃគូ ដែលមានបទពិសោធធ្លាប់ទទួលរងអំពើហិង្សាដោយដៃគូជិតស្និទ្ធ បានរាយការណ៍ថាពួកគេធ្លាប់ខកខានមិនបានទៅធ្វើការរកកម្រៃយ៉ាងហោចណាស់មួយថ្ងៃ ក្នុងរយៈពេល ១២ ខែចុងក្រោយ ដោយសារតែបទពិសោធនៃអំពើហិង្សាដែលខ្លួនបានជួប។

ជាមធ្យម ស្ត្រីបានរាយការណ៍ថាខ្លួនខកខានមិនបានទៅធ្វើការរកកម្រៃចំនួន ៣ ថ្ងៃ ក្នុងរយៈពេល ១២ ខែចុងក្រោយ ដោយសារតែបទពិសោធនៃអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទដែលខ្លួនបានជួប។ ១១% នៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូក៏បានរាយការណ៍ថាពួកគេមិនអាចបំពេញការងារគ្មានប្រាក់កម្រៃរបស់ខ្លួនយ៉ាងហោចណាស់មួយថ្ងៃ ក្នុងអំឡុងពេល ១២ ខែចុងក្រោយ។

៦/ យុទ្ធសាស្ត្រទប់ទល់របស់ស្ត្រី និងការឆ្លើយតបចំពោះអំពើហិង្សាប្រព្រឹត្តិដោយដៃគូ

ពាក់កណ្តាលនៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូជិតស្និទ្ធទាំងអស់ មិនធ្លាប់ប្រាប់នរណាម្នាក់អំពីរឿងនេះទេ ហើយបើសិនជាគេនិយាយប្រាប់ នោះភាគច្រើនគេប្រាប់ទៅគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង

ស្ទើរតែពាក់កណ្តាល(៤៩%)នៃស្ត្រីដែលបានរាយការណ៍ថាធ្លាប់មានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ មិនធ្លាប់បានប្រាប់នរណាម្នាក់អំពីអំពើហិង្សានេះទេ។

ស្ទើរតែពាក់កណ្តាល (៤៩%) នៃស្ត្រីដែលបានរាយការណ៍ថាធ្លាប់មានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ មិនធ្លាប់បានប្រាប់នរណាម្នាក់អំពីអំពើហិង្សានេះទេ។ចំណុចនេះមានន័យថាសម្រាប់ស្ត្រីជាច្រើនបានរាយការណ៍ថា មន្ត្រីសម្ភាសន៍គឺជាមនុស្សដំបូងបំផុត ដែលពួកគេបានបង្ហាញប្រាប់អំពីអំពើហិង្សានេះ។ ក្នុងចំណោមស្ត្រីដែលធ្លាប់បានប្រាប់នរណាម្នាក់អំពីអំពើហិង្សា ភាគច្រើនគឺពួកគេប្រាប់ទៅសមាជិកគ្រួសារ ឬអ្នកជិតខាងរបស់ខ្លួន។

មានតែ ២៤% ប៉ុណ្ណោះនៃស្ត្រីដែលមានបទពិសោធជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទ ប្រព្រឹត្តដោយដៃគូដែលធ្លាប់ស្វែងរកជំនួយផ្លូវការពីសេវានានា

ក្នុងចំណោមស្ត្រីដែលមានបទពិសោធន៍ជួបអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទប្រព្រឹត្តដោយដៃគូជិតស្និទ្ធ មានតែ ២៤% ប៉ុណ្ណោះដែលស្វែងរកជំនួយពីសេវាផ្លូវការ។ សម្រាប់អ្នកដែលបានទៅរកជំនួយពីសេវា ភាគច្រើនពួកគេទៅរកអ្នកដឹកនាំក្នុងមូលដ្ឋាន (១៥%) ឬទៅរកប៉ូលីស (១១%)។ មានតែ ២% ប៉ុណ្ណោះនៃស្ត្រីដែលបានទៅរកជំបូន្មានផ្នែកច្បាប់ ឬទៅរកតុលាការឲ្យជួយ។ ចំណុចនេះអាចបញ្ជាក់ឲ្យឃើញថា ចាំបាច់ត្រូវធ្វើឲ្យវិស័យច្បាប់ និងយុត្តិធម៌ កាន់តែមានលក្ខណៈងាយស្រួលជាងនេះ សម្រាប់ឲ្យស្ត្រីចូលទៅរក ហើយវាក៏អាចឆ្លុះបញ្ចាំងឲ្យឃើញផងដែរថា ស្ត្រីជាច្រើនពុំចង់ឃើញដៃគូរបស់ខ្លួនរងទោសឧក្រិដ្ឋនោះឡើយ បើទោះបីជាពួកគេចង់ឲ្យអំពើហិង្សាត្រូវបានបញ្ឈប់ក្តី។ គ្លីនិកសុខភាព (៥%) និងជម្រកសុវត្ថិភាព (៥%) ក៏ត្រូវបានស្ត្រីដែលមានបទពិសោធន៍ជួបអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូរាយការណ៍ថាជាកន្លែងដែលពួកគេធ្លាប់បានទៅរកជំនួយផងដែរ។ នេះជាទម្រង់សាមញ្ញដែលកើតមាននៅទូទាំងសាកលលោក ប៉ុន្តែនេះក៏ជាចំណុចមួយដែលបង្ហាញឲ្យឃើញច្បាស់ថា សេវាទាំងឡាយត្រូវធ្វើយ៉ាងណាឲ្យមានលក្ខណៈកក់ក្តៅចំពោះអ្នកដែលបានរួចផុតពីអំពើហិង្សា និងធ្វើឲ្យពួកគេអាចមានលទ្ធភាពចូលទៅរកឲ្យច្រើនជាងនេះ ហើយដោយសារតែមានស្ត្រីក្នុងចំនួនតិចតួចប៉ុណ្ណោះដែលបានស្វែងរកជំនួយផ្លូវការ ហេតុនេះ ចាំបាច់ត្រូវមានអន្តរាគមន៍ដែលផ្តោតលើប្រជាជនទូទៅ។

ស្ត្រីភាគច្រើនដែលបានរាយការណ៍ថាបានស្វែងរកជំនួយ គឺដោយសារតែភាពធ្ងន់ធ្ងរ និងផលប៉ះពាល់នៃអំពើហិង្សា ប៉ុន្តែស្ត្រីជាច្រើនមិនស្វែងរកជំនួយព្រោះពួកគេគិតថាអំពើហិង្សាជារឿងធម្មតា ឬដោយសារពួកគេមានការអៀនខ្មាស់

ស្ត្រីដែលបានរាយការណ៍ថាធ្លាប់បានទៅរកសេវាជំនួយយ៉ាងហោចណាស់មួយ បានរាយការណ៍ថាពួកគេទៅរកសេវានោះគឺដោយសារតែពួកគេមិនអាចទ្រាំនឹងអំពើហិង្សាតទៅទៀតបាន និងដោយសារតែគាត់ខ្លាចថាអំពើហិង្សានឹងមានសភាពកាន់តែអាក្រក់ឡើង (សូមមើលរូបភាពទី ១០)។ ស្ត្រីជាច្រើនក៏បានរាយការណ៍ថា ពួកគេត្រូវបានគ្រួសារ និងមិត្តភក្តិលើកទឹកចិត្តឲ្យទៅរកជំនួយ ឬពួកគេបានទៅរកជំនួយដោយសារតែពួកគេមើលឃើញថាកូនៗរបស់ខ្លួនរងការឈឺចាប់ដោយសារតែអំពើហិង្សា។

៤0% នៃស្ត្រីដែលមិនបានស្វែងរកសេវាជំនួយ បានបញ្ជាក់ថា ពួកគេមិនចង់ស្វែងរកជំនួយព្រោះពួកគេជឿថា អំពើហិង្សាគឺជារឿង “ធម្មតា” ឬមិន “ធ្ងន់ធ្ងរ”។

ហេតុផលដទៃទៀតដែលត្រូវបានលើកឡើងគឺដោយសារតែខ្លាចខ្មាស់គេ ឬភាពអាម៉ាស់ ឬពួកគេខ្លាចបាត់បង់កូន ឬខ្លាចនាំភាពអាម៉ាស់មកឲ្យគ្រួសារ។

រូបភាពទី ១០៖

ហេតុផលដើម្បីស្វែងរកជំនួយ (ក្នុងចំណោមស្ត្រីដែលបានស្វែងរកជំនួយ) និងមិនស្វែងរកជំនួយ (ក្នុងចំណោមស្ត្រីដែលមិនបានស្វែងរកជំនួយ) តាមលំដាប់នៃការឆ្លើយតបដែលត្រូវបានលើកឡើងច្រើនបំផុត

១៥៣

ហេតុផលដែលស្វែងរកជំនួយ (n=១៥៣)

- មិនអាចទ្រាំតទៅទៀតបាន
- គ្រួសារ/មិត្តភក្តិលើកទឹកចិត្ត
- ខ្លាចមានអំពើហិង្សាកាន់តែធ្ងន់ថែមទៀត
- ឃើញថាកូនៗកំពុងរងការឈឺចាប់
- ដៃគូរគម្រាម/វាយកូនៗ
- រងរបួសធ្ងន់ធ្ងរ
- ខ្លាចថាបុរសនោះនឹងសម្លាប់ខ្លួន
- ត្រូវបានធ្វើឲ្យឃ្លាតចេញពីផ្ទះ
- ខ្លាចថាខ្លួននឹងសម្លាប់បុរសនោះ

៤៨១

ហេតុផលដែលមិនស្វែងរកជំនួយ (n=៤៨១)

- អំពើហិង្សានោះត្រូវបានចាត់ទុកជារឿងធម្មតា/មិនធ្ងន់ធ្ងរ
- ខ្លាចខ្មាសគេ ឬភាពអាម៉ាស់
- ខ្លាចថាខ្លួននឹងត្រូវបាត់បង់កូន
- មានអារម្មណ៍ថាខ្លួននឹងអាចនាំឈ្មោះអាក្រក់មកឲ្យគ្រួសារ
- ខ្លាចការគម្រាម ឬលទ្ធផលដែលនឹងអាចកើតមាន
- ខ្លាចបែកបាក់ទំនាក់ទំនង
- ជឿថាគ្មាននរណាជួយគាត់ទេ
- មិនដឹងទៅរកគេជួយនៅឯណា

ភាគច្រើននៃស្ត្រីដែលស្ថិតក្នុងទំនាក់ទំនងប្រកបដោយការរំលោភបំពានភាគច្រើនពុំចាកចេញពីគ្នា នោះទេ។ ក្នុងចំណោមស្ត្រីដែលបានចាកចេញពីទំនាក់ទំនងប្រកបដោយការរំលោភបំពានជាបណ្តោះអាសន្ន ក្រោយមកបានត្រលប់មកវិញ ព្រោះពួកគេមិនចង់ចាកចេញពីកូនរបស់ខ្លួន



នៃស្ត្រីដែលធ្លាប់មានបទពិសោធន៍ជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូបានរាយការណ៍ថាគាត់មិនដែលបានចាកចេញពីផ្ទះដោយសារតែអំពើហិង្សានោះទេ។

ហេតុផលដែលធ្វើឲ្យស្ត្រីភាគច្រើនចាកចេញពីផ្ទះ គឺប្រហាក់ប្រហែលគ្នានឹងហេតុផលដែលពួកគេចេញទៅរកជំនួយដែរ ហើយបានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពធ្ងន់ធ្ងរនៃអំពើហិង្សា និងកង្វល់អំពីសុខមាលភាពរបស់កូនៗ។ ប៉ុន្តែ ហេតុផលសាមញ្ញបំផុតដែលត្រូវបានលើកឡើងដោយស្ត្រីដែលបានត្រលប់មកផ្ទះវិញក្រោយពេលចាកចេញជាបណ្តោះអាសន្ននោះគឺដោយសារតែពួកគេមិនចង់ចាកចេញពីកូនៗ (៤៧%) និងព្រោះតែដៃគូរបស់ពួកគេបានសុំឲ្យពួកគេត្រលប់មកវិញ (៣0%)។ ស្រដៀងគ្នានេះដែរ ស្ត្រីដែលជ្រើសរើសមិនចាកចេញទាល់តែសោះ ភាគច្រើនបានរាយការណ៍ថាដោយសារតែពួកគេមិនចង់ចាកចេញពីកូន។ ហេតុផលសាមញ្ញបន្ទាប់ទៀតដែលស្ត្រីបានលើកឡើងថាជាមូលហេតុដែលខ្លួនមិនចាកចេញ បើទោះបីជាមានករណីហិង្សា ក៏ដោយនោះគឺ ដោយសារតែពួកគេជឿថាអំពើហិង្សានោះជារឿងធម្មតា (១៧%)។ ចម្លើយនេះគឺស្របគ្នាជាមួយនឹងហេតុផលនៅពីក្រោយការសម្រេចចិត្តរបស់ស្ត្រីជាច្រើនក្នុងការមិនទៅរកជំនួយ ឬទៅរកសេវានានាឲ្យជួយផងដែរ។

៧/ កត្តាហានីភ័យ និងកត្តាការពារដែលពាក់ព័ន្ធនឹងបទពិសោធន៍របស់ស្ត្រីជាមួយនឹងអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តដោយដៃគូរជិតស្និទ្ធ

ការវិភាគបែប Multi-variate logistic regression ត្រូវបានយកមកអនុវត្តដើម្បីឲ្យយើងយល់កាន់តែច្បាស់អំពីកត្តានានាដែលបង្កើនហានីភ័យរបស់ស្ត្រីក្នុងការជួបនឹងបទពិសោធហិង្សាប្រព្រឹត្តិដោយដៃគូ ឬកត្តានានាដែលការពារស្ត្រីពីអំពើហិង្សានោះ។ លទ្ធផលនៃការវិភាគរកឃើញនូវចំណុចខាងក្រោមនេះថាជាកត្តាគួរឲ្យកត់សម្គាល់ទាក់ទងនឹងបទពិសោធរបស់ស្ត្រីជាមួយអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទប្រព្រឹត្តិដោយដៃគូ៖



កម្រិតសិក្សាទាបរបស់អ្នកតបសម្ភាសន៍

មានដៃគូជាបុគ្រឿងស្រវឹង(យ៉ាងហោចណ
ឬពីរដងក្នុងមួយ

កត្តានានាដែលបង្កើនហានីភ័យរបស់ស្ត្រីក្នុងការជួបនឹងបទពិសោធន៍ហិង្សាប្រព្រឹត្តិដោយដៃគូ

អ្នកតបសម្ភាសន៍ធ្លាប់ឃើញម្តាយរបស់ខ្លួនរងការរំលោភបំពានពេលខ្លួននៅជាកុមារ



មានដៃគូជាបុរសដែលមានលក្ខណៈហិង្សាចំពោះបុរសដទៃទៀត

អ្នកតបសម្ភាសន៍ធ្លាប់មានបទពិសោធរងនូវអំពើហិង្សាផ្លូវកាយពេលនៅជាកុមារ

អ្នកតបសម្ភាសន៍មាន
ឥរិយាបថដែលចាត់ទុកថាការប្រើ
ហិង្សារបស់ប្តី
មកលើប្រពន្ធ
ជារឿងមានហេតុផល
ត្រឹមត្រូវ ឬជារឿងធម្មតា

រសធឹក
ាប្រចាំ
ាសម្តង
សប្តាហ៍)

នដៃគូជាបុរស
លមានស្ត្រីផ្សេង
ពេលដំណាលគ្នាដែល
សនោះនៅជាមួយ
តបសម្ភាសន៍ដែរ





មានដៃគូជាបុរសដែលមាន
លក្ខណៈត្រួតត្រា
លើអ្នកឆ្លើយតប។

ទោះយ៉ាងណាក្តី កត្តាតែម្យ៉ាងពុំមែនសុទ្ធតែបង្កឲ្យមានហិង្សានោះទេ ហើយពុំបានដំណើរការក្នុងលក្ខណៈដាច់តែឯងនោះដែរ។ ផ្ទុយទៅវិញ កត្តាទោលជាច្រើនរួមគ្នាឆ្លុះបញ្ចាំងនូវបរិបទទូលំទូលាយដែលស្ថិតនៅពីក្រោយវិសមភាពផ្នែកយេនឌ័រ និងអតុល្យភាពអំណាចរវាងស្ត្រី និងបុរស។ នៅក្នុងបរិបទសង្គមដែលទូលំទូលាយ កត្តាទោលនីមួយៗខាងលើ បង្កើតឲ្យមាន និងឆ្លុះបញ្ចាំងឲ្យឃើញនូវនិយាមសង្គម រចនាសម្ព័ន្ធសង្គម និងគុណតម្លៃក្នុងសង្គមដែលទាក់ទងជាមួយយេនឌ័រ និងអំណាច ហើយនៅតែជាកត្តាជំរុញដែលស្ថិតនៅពីក្រោយ ឬជាមូលដ្ឋានគ្រឹះនៃអំពើហិង្សាប្រឆាំងស្ត្រី។

បទពិសោធហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធដែលស្ត្រីជួបប្រទះ ត្រូវបានជំរុញមួយផ្នែកដោយវិសមភាពយេនឌ័រ និងការចាត់ទុកអំពើហិង្សាថាជារឿងធម្មតា

គំនិតចាក់ឫសអំពីវិសមភាពយេនឌ័រ និងនិយាមការលើកលែងទោសចំពោះអំពើហិង្សា គឺពាក់ព័ន្ធនឹងការប្រព្រឹត្តិល្មើស និងបទពិសោធន៍ជាមួយអំពើហិង្សា។

ជាទូទៅ ស្ត្រីក្នុងប្រទេសកម្ពុជាដែលជឿថាក្នុងកាលៈទេសៈមួយចំនួន ប្តីមានមូលហេតុដើម្បីវាយប្រពន្ធ គឺច្រើនតែមានបទពិសោធន៍ជួបនឹង IPV ក្នុងកម្រិតគួរឲ្យកត់សម្គាល់ បើប្រៀបធៀបជាមួយស្ត្រីដែលមិនមានជំនឿដូច្នេះ។

ចំណុចនេះ ស្តែងឲ្យឃើញនូវសារៈសំខាន់ក្នុងការជំនះនូវគំនិតដែលចាត់ទុកអំពើហិង្សាលើស្ត្រីជារឿងធម្មតា។

ការអប់រំគឺជាកត្តាការពារគន្លឹះសម្រាប់ស្ត្រីប្រឆាំងនឹងអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធ

ការអប់រំរបស់ស្ត្រី ឆ្លុះបញ្ចាំង ឲ្យឃើញនូវភាពអង់អាចផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ស្ត្រី ហើយត្រូវបានរកឃើញថាជាកត្តា ការពារដ៏សំខាន់ទប់ទល់នឹងអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធនៅក្នុងការសិក្សានេះ ។ការសិក្សារកឃើញថា ស្ត្រីដែលមានការអប់រំដល់កម្រិតមធ្យមសិក្សា ឬលើសពីនេះ ច្រើនតែមិនសូវមានបទពិសោធជួបអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធទេ បើប្រៀបធៀបជាមួយស្ត្រីដែលរៀនបានត្រឹមតែកម្រិតបឋមសិក្សា ឬមិនបានរៀនសូត្រ។

បទពិសោធនៃអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធរបស់ស្ត្រី ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងគំរូភាពជាបុរសដែលជំរុញឲ្យមានអំពើហិង្សា

បើនិយាយអំពីបុគ្គលិកលក្ខណៈរបស់បុរសវិញ អាកប្បកិរិយាត្រួតត្រា ការចូលរួមនៅក្នុងការវាយតប់ជាមួយបុរសដទៃ ទំនាក់ទំនងក្រៅចំណងអាពាហ៍ពិពាហ៍ និងការប្រើប្រាស់គ្រឿងស្រវឹងបំពាន ត្រូវបានរកឃើញថាមានចំណងទាក់ទងយ៉ាងខ្លាំងជាមួយបទពិសោធន៍ហិង្សាដែលស្ត្រីជួបប្រទះ។ កត្តាទាំងអស់នេះបូករួមគ្នាឆ្លុះបញ្ចាំងឲ្យឃើញនូវគំរូភាពជាបុរសមួយ ដែលជាប់ទាក់ទងនឹងការគ្របដណ្តប់ និងការត្រួតត្រាលើស្ត្រី ភាពស្និតស្នាញ និងកម្លាំង និងការអនុវត្តក្នុងទំនាក់ទំនងភេទផ្ទុយគ្នា។ ទម្រង់អាកប្បកិរិយាទាំងអស់នេះរួមបញ្ចូលគ្នា ជួយជម្រុញនូវវិសមភាពយេនឌ័រ និងបង្កើនលទ្ធភាពកើតមានអំពើហិង្សាលើស្ត្រី។

ស្ត្រីដែលបានឃើញ ឬធ្លាប់មានបទពិសោធន៍ជួបអំពើហិង្សាពេលខ្លួននៅជាកុមារ ប្រឈមហានីភ័យកាន់តែខ្ពស់ចំពោះបទពិសោធហិង្សាប្រព្រឹត្តិដោយដៃគូ ជាការបញ្ជាក់ឲ្យឃើញថាមួយផ្នែកនៃអំពើហិង្សាជាការរៀនសូត្រពីសង្គម ហើយត្រូវសង្គមចាត់ទុកថាជារឿងធម្មតា

ស្ត្រីដែលធ្លាប់ឃើញម្តាយខ្លួនរងការរំលោភបំពាន ឬខ្លួនគាត់ផ្ទាល់ធ្លាប់ជួបបទពិសោធអំពើហិង្សាពេលនៅជាកុមារ ច្រើនតែជួបបទពិសោធ អំពើហិង្សាដោយដៃគូជិតស្និទ្ធ។ ចំណងទាក់ទងរវាងការដាក់ទណ្ឌកម្មផ្នែករាងកាយក្នុងកុមារភាព និងអំពើហិង្សាក្នុងគ្រួសាររបស់មនុស្សធំ ស្នើឲ្យឃើញថា ការវាយដំកុមារ ធ្វើឲ្យអំពើហិង្សាត្រូវបានចាត់ទុកថាជារឿងធម្មតា ហើយហិង្សាក្លាយជាទម្រង់មួយនៃការដោះស្រាយបញ្ហា និងការដាក់ទណ្ឌកម្ម។ ហេតុនេះកុមាររស់នៅក្នុងផ្ទះដែលមានហិង្សាច្រើនតែរៀនប្រើហិង្សាជំនួសឲ្យរៀនរបៀបដោះស្រាយជម្លោះក្នុងលក្ខណៈស្ថាបនា និងដោយសន្តិវិធី ហើយពួកគេច្រើនតែធ្លាក់ជាជនរងគ្រោះផងដែរ។ កុមារដែលធ្លាប់បានឃើញអំពើហិង្សា ក៏ច្រើនតែមានបទពិសោធជួបនឹងបញ្ហាផ្នែកអាកប្បកិរិយា និងផ្នែកអារម្មណ៍ជាទៃទៀតជាច្រើន ពេលពួកគេធំឡើងផងដែរ។ ចំណុចនេះសង្កត់ធ្ងន់ឲ្យយើងឃើញអំពីភាពចាំបាច់កាន់តែខ្លាំងថែមទៀតក្នុងការទប់ស្កាត់ការរំលោភបំពានលើកុមារ និងការលើកកម្ពស់បរិដ្ឋានគ្រួសារ និងសាលារៀនដែលមានលក្ខណៈជាវិជ្ជមាន និងគ្មានអំពើហិង្សា។

ការប្រើប្រាស់គ្រឿងស្រវឹងបំពាន ក៏អាចជំរុញឲ្យអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធផ្ទុះឡើងដែរ

ការប្រើប្រាស់គ្រឿងស្រវឹងដោយដៃគូរបស់អ្នកឆ្លើយតប ត្រូវបានរកឃើញថាមានភាពពាក់ព័ន្ធជាវិជ្ជមានជាមួយអំពើហិង្សាដោយដៃគូជិតស្និទ្ធ ដែលចំណុចនេះ មានភាពស្របគ្នាជាមួយការសិក្សាដទៃទៀតដែរ។ ប៉ុន្តែ យើងត្រូវដាក់តួនាទីរបស់គ្រឿងស្រវឹងនៅក្នុងបរិបទទូលំទូលាយនៃវិសមភាពយេនឌ័រ និងអតុល្យភាពអំណាចរវាងបុរសនិងស្ត្រី ព្រោះថាវប្បធម៌ជុំវិញការផឹកគ្រឿងស្រវឹង គឺផ្សារភ្ជាប់ជាមួយគំរូភាពជាបុរស ដែលលើកកម្ពស់អំពើហិង្សាលើស្ត្រី (Brickell 2008; McIlwaine and Moser 2004; Alcarez and Suarez 2006) ។ ឯកសារស្តីពីអំពើហិង្សាដែលស្ត្រីជួបប្រទះ ស្នើឲ្យឃើញថា តួនាទីគ្រឿងស្រវឹងគឺផ្អែកទៅតាមបរិបទជាក់លាក់ ហើយពេលដែលរួមផ្សំជាមួយកត្តាផ្សេងៗទៀត ធ្វើឲ្យគ្រឿងស្រវឹងក្លាយជាកត្តាជំរុញឲ្យករណីហិង្សាផ្ទុះឡើង ជាជាងបុព្វហេតុដែលបង្កឲ្យមានហិង្សា។ គ្រឿងស្រវឹងត្រូវបានគេមើលឃើញថាបានចូលរួមវិភាគទានចំពោះអំពើហិង្សា ដោយបានជាស់ឲ្យមានដម្លោះកាត់បន្ថយភាពអត់ទ្រាំ និងផ្តល់ទីតាំងផ្អែកសង្គមសម្រាប់ការជាក់ទណ្ឌកម្មនៅកម្រិតគ្រួសារ (Jewkes, Levin and Penn-Kekana 2002; Lee, 2007) ។ ប៉ុន្តែ ជាការចាំបាច់ដែលត្រូវចងចាំថា ការប្រើប្រាស់គ្រឿងស្រវឹង មិនបានពន្យល់អំពីឫសគល់នៃអតុល្យភាពអំណាចនៅក្នុងទំនាក់ទំនងដែលដៃគូម្ខាងប្រើប្រាស់ការត្រួតត្រាដោយបង្ខំលើដៃគូម្ខាងទៀតនោះឡើយ។ ហេតុនេះ កម្មវិធីទប់ស្កាត់ ដែលផ្តោតគោលដៅលើអំពើហិង្សាលើស្ត្រី មិនគួរផ្តោតតែទៅលើការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងតែមួយមុខ ហើយសង្ឃឹមថាវានឹងលុបបំបាត់ អំពើហិង្សាលើស្ត្រីនោះឡើយ។

សន្និដ្ឋាន និងអនុសាសន៍

ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធក្នុងជីវិតរបស់ស្ត្រី គឺជាការស្ទាបស្ទង់មតិដែលផ្អែកលើប្រជាសាស្ត្រដំបូងបំផុតដែលវាស់វែងលើអត្រាសាយភាយនៃបទពិសោធស្ត្រីចំពោះអំពើហិង្សាលើស្ត្រី និងលទ្ធផលផ្នែកសុខភាពរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ ការសិក្សានាពេលកន្លងមក បានចង្អុលបង្ហាញអំពីធម្មជាតិដ៏សាយភាយនៃអំពើហិង្សាប្រឆាំងស្ត្រីក្នុងប្រទេសកម្ពុជា ហើយការសិក្សានេះ បានអះអាងពីភាពត្រឹមត្រូវនៃការស្រាវជ្រាវកន្លងមក (CDHS, 2014?; Fulu et al., 2013)។

ការសិក្សាស្រាវជ្រាវដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនេះ បង្ហាញឲ្យឃើញថា ស្ត្រីប្រឈមនឹងហានិភ័យកាន់តែខ្ពស់នៃអំពើហិង្សាប្រព្រឹត្តិដោយដៃគូជិតស្និទ្ធរបស់ពួកគេ ហើយតាមធម្មតា អំពើហិង្សានេះតែងកើតមានជាញឹកញាប់ និងធ្ងន់ធ្ងរ។ អំពើហិង្សាដោយដៃគូជិតស្និទ្ធ រួមមានទាំងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ហេតុនេះហើយ ការទប់ស្កាត់ និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះអំពើហិង្សាលើស្ត្រី និងកុមារីទាមទារនូវយុទ្ធសាស្ត្របែបរួមបញ្ចូល ការប្តេជ្ញាចិត្តរយៈពេលវែង និងការសម្របសម្រួលរវាងភាគីពាក់ព័ន្ធសំខាន់ៗ។ ស្ត្រីក៏មានបទពិសោធជួបនឹងអំពើហិង្សាប្រព្រឹត្តិដោយជនមិនមែនជាដៃគូផងដែរ ថ្វីបើជារឿយៗជននោះជាមនុស្សដែលខ្លួនធ្លាប់ស្គាល់ក្តី។

សរុបមក ការសិក្សាបង្ហាញថា អំពើហិង្សាលើស្ត្រី គឺជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយ ដែលមានផលប៉ះពាល់រយៈពេលវែងចំពោះផ្លូវកាយ ផ្លូវចិត្ត និងសុខភាពបន្តពូជ។ បន្ថែមលើនេះទៀត បទពិសោធអំពើហិង្សាដែលស្ត្រីធ្លាប់ជួប មានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើសុខមាលភាពកូនៗរបស់ពួកគេលើផលិតភាពរបស់ពួកគេ និងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម។

ការវិភាគទៅលើកត្តានានាពាក់ព័ន្ធនឹងបទពិសោធន៍របស់ស្ត្រីចំពោះអំពើហិង្សាបង្ហាញថា ការបញ្ចប់អំពើហិង្សាលើស្ត្រីទាមទារនូវការផ្តល់ភាពអង់អាចដល់ស្ត្រីយ៉ាងពេញលេញ តាមរយៈការលុបបំបាត់វិសមភាពយេនឌ័រ និងការរើសអើង ជាពិសេសគឺអ្វីដែលត្រូវបានអនុវត្តតាមរយៈនិយាមសង្គម ដែលលើកទឹកចិត្តចំពោះគំរូភាពជាបុរសដែលផ្អែកលើភាពគ្របដណ្តប់លើស្ត្រី និងបំផ្លិចបំផ្លាញសិទ្ធិស្ត្រី។ រួមជាមួយគ្នានេះដែរ ការឆ្លើយតបចំពោះការប្រព្រឹត្តិមិនល្អចំពោះកុមារនិងការប្រើប្រាស់គ្រឿងស្រវឹងបំពាន ព្រមទាំងការធានានូវការអប់រំរបស់ស្ត្រី គឺមានភាពចាំបាច់បំផុតដើម្បីដោះស្រាយបញ្ហាអំពើហិង្សាប្រឆាំងស្ត្រី។ ជាការចាំបាច់ណាស់ដែលត្រូវអភិវឌ្ឍកម្មវិធីដួយលើកកម្ពស់បរិដ្ឋានគ្រួសារ ផ្ទះ និងសហគមន៍ដែលមានលក្ខណៈជាវិជ្ជមាន និងគ្មានហិង្សា ដោយផ្អែកលើសមភាពយេនឌ័រ និងការគោរព។

រាជរដ្ឋាភិបាលកម្ពុជា បានឈានជាជំហានរួចមកហើយនៅក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនិងកុមារីតាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទីមួយ និងលើកទីពីរ។

អនុសាសន៍ខាងក្រោមនេះ ឆ្លុះបញ្ចាំងឲ្យឃើញនូវការរកឃើញសំខាន់ៗជាក់លាក់នៅក្នុងការសិក្សានេះ ប៉ុន្តែ ដោយផ្អែកលើសមិទ្ធផលដែលរដ្ឋាភិបាលសម្រេចបានរហូតមកទល់ពេលនេះផងដែរ។ អនុសាសន៍ខាងក្រោម ត្រូវបានទាញចេញភាគច្រើនមកពីផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ហើយមានបំណងបំពេញបន្ថែម និងគាំទ្រចំពោះក្របខ័ណ្ឌការងារថ្នាក់ជាតិ និងអភិក្រមសម្រាប់កិច្ចបង្ការ និងការឆ្លើយតប។ ជាទូទៅ ការទប់ស្កាត់អំពើហិង្សា និងផែនការឆ្លើយតប គួរតែមានលក្ខណៈពហុវិស័យ ផ្សារភ្ជាប់ជាមួយគ្នាទៅវិញទៅមក និងត្រូវបានសម្របសម្រួលក្នុងលក្ខណៈជាយុទ្ធសាស្ត្រ។ ការទប់ស្កាត់អំពើហិង្សា និងផែនការឆ្លើយតបទាំងនោះ ក៏គួរត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌការងារ និងផែនការ អភិវឌ្ឍន៍សង្គម សមភាពយេនឌ័រ និងសិទ្ធិមនុស្សដែលមានលក្ខណៈទូលំទូលាយ។

អំពើហិង្សាលើស្ត្រី គឺជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយ ដែលមានផលប៉ះពាល់រយៈពេលវែងចំពោះផ្លូវកាយ ផ្លូវចិត្ត និងសុខភាពបន្តពូជ

រចនាដោយ៖ Melon Rouge Agency

រក្សាសិទ្ធរូបភាពដោយ៖

Cover, @Nicolas Axelrod / Ruom. ទំព័រ ៦, @Nicolas Axelrod / Ruom. ទំព័រ ១១, © Thomas Cristofoletti / Ruom. ទំព័រ ១២, @Fani Llauradó. ទំព័រ ១៦, @Todd Brown. ទំព័រ ២២, @Todd Brown. ទំព័រ ២៤, © Thomas Cristofoletti / Ruom. ទំព័រ ២៩, © Thomas Cristofoletti / Ruom. ទំព័រ ៣៣, @Todd Brown. ទំព័រ ៣៤ @Todd Brown

សមាជិកគណៈកម្មការ ក្រុមអ្នកស្រាវជ្រាវប្រចាំប្រទេស ក្រុមអ្នកស្រាវជ្រាវបង្គោល និងក្រសួង/ស្ថាប័ន/អង្គការ ដែលបានចូលរួម និងសម្របសម្រួលការសិក្សាស្រាវជ្រាវនេះ

សមាជិកគណៈកម្មការដឹកនាំ ៖

លោកជំទាវ ស៊ី ដេហ្វីន	រដ្ឋលេខាធិការ	ក្រសួងកិច្ចការនារី
លោកជំទាវ អ៊ុំ សាម៉ុល	អនុរដ្ឋលេខាធិការ	ក្រសួងសុខាភិបាល
លោកជំទាវ ច័ន្ទ ហារ៉ានវដ្តី	អនុរដ្ឋលេខាធិការ	ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លោកជំទាវ ប៊ូ សោភ័ណ	អគ្គលេខាធិការរង	ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
លោកជំទាវ ច័ន្ទ ធី	រដ្ឋលេខាធិការ	ក្រសួងព័ត៌មាន
លោកជំទាវ ទូច សារ៉ុម	រដ្ឋលេខាធិការ	ក្រសួងធម្មការ និងសាសនា
លោកជំទាវ ទេស ច័ន្ទសារឿន	អនុរដ្ឋលេខាធិការ	ក្រសួងកិច្ចការនារី
លោកជំទាវ ហង់ លីណា	អគ្គនាយក	វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ
លោកជំទាវ ហ៊ុន ដានី	អនុរដ្ឋលេខាធិការ	ក្រសួងទេសចរណ៍
ឯកឧត្តម ហ៊ាង ស៊ីណេ	អនុរដ្ឋលេខាធិការ	ក្រសួងអប់រំ យុវជន និងកីឡា
លោកជំទាវ សួស រដ្ឋាវី	អនុរដ្ឋលេខាធិការ	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ឯកឧត្តម សេង សុមុនី	អនុរដ្ឋលេខាធិការ	ក្រសួងធម្មការ និងសាសនា
លោកជំទាវ សឿ សុជាតា	អនុរដ្ឋលេខាធិការ	ក្រសួងអប់រំ យុវជន និងកីឡា
លោកជំទាវ ខៀវ សិរីវុឌ្ឍា	ទីប្រឹក្សា	ក្រសួងកិច្ចការនារី
លោកជំទាវ ឈូក ឈូងៀ	ទីប្រឹក្សា	ក្រសួងទេសចរណ៍
ឯកឧត្តម តូច ចាន់នី	អគ្គនាយកបច្ចេកទេស ក្រសួងសង្គមកិច្ច	អតីតយុទ្ធជន និងយុវនីតិសម្បទា
លោកជំទាវ ញ៉ែប សុភាព	អគ្គលេខាធិការរង	ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ
ឯកឧត្តម ហោ ប៊ុនឡេង	អគ្គលេខាធិការរង	អជ្ញាធរជាតិប្រយុទ្ធនឹង ជម្ងឺអេដស៍
លោកស្រី ជូ ពុទ្ធានី	អគ្គនាយករង	ក្រសួងផែនការ
លោកស្រី ម៉ៅ កីរុណ	អគ្គនាយករង	ក្រសួងយុត្តិធម៌
លោកស្រី ស្វាយ ស៊ីសារ៉ុត	អគ្គាធិការរង	ក្រសួងយុត្តិធម៌
លោកស្រីទុង រដ្ឋាវី	ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក	ក្រសួងសុខាភិបាល

លោក ថី ឃាម	ប្រធាននាយកដ្ឋាន វិទ្យាស្ថានជាតិស្ថិតិ	ក្រសួងផែនការ
លោក ចាន់ សុភា	ប្រធាននាយកដ្ឋាន	ក្រសួងអប់រំ យុវជន និងកីឡា
លោក ជីវ ផល្លី	អនុប្រធាននាយកដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ	ក្រសួងមហាផ្ទៃ
លោកស្រី ណា នាង	អនុប្រធាននាយកដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ	ក្រសួងមហាផ្ទៃ
លោក ភួង សុភី	នាយការិយាល័យ អគ្គស្នងការដ្ឋាននគរបាលជាតិ	ក្រសួងមហាផ្ទៃ

ក្រុមស្រាវជ្រាវប្រចាំប្រទេស

លោកជំទាវ ស៊ី ដេហ្វីន, រដ្ឋលេខាធិការ, ក្រសួងកិច្ចការនារី
លោកជំទាវ ហង់ លីណា, ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
លោក ថី ឃាម, ប្រធាននាយកដ្ឋាន, វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ
លោក សាំង ឡងឌី, ប្រធាននាយកដ្ឋាន, វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

ក្រុមស្រាវជ្រាវបង្គោល

ដេប៊ី គ្រេ, អង្គការសុខភាពពិភពលោកប្រចាំនៅប្រទេសកម្ពុជា
គ្រីស្ទីណា ផាលីតូ, អង្គការសុខភាពពិភពលោកប្រចាំនៅទីក្រុងហ្សឺណែវ
ឃ្លោដៀ ហ្គាសៀ ម៉ូរេណូ, អង្គការសុខភាពពិភពលោកប្រចាំនៅទីក្រុងហ្សឺណែវ
អាន់ចាណា ប៊ូសាន, អង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិចខាងលិច
ប្រឺតតា ប៉ៀ, អង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិចខាងលិច
ហេនរីកា អេ អេហ្វ អឹម (ហេម រៀត) ចេន សិន ទីប្រឹក្សាអង្គការសុខភាពពិភពលោក និងមូលនិធិសហប្រជាជាតិដើម្បីប្រជាជន ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច

ស្ថាប័នជំនួយ

ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រីប្រចាំនៅកម្ពុជា តាមរយៈកម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាលអូស្ត្រាលី

ស្ថាប័នដែលបានចូលរួមនានា

មូលនិធិសហប្រជាជាតិដើម្បីកុមារ
មូលនិធិសហប្រជាជាតិដើម្បីប្រជាជន
សេវាសង្គកិច្ចកម្ពុជា
គ្លីនិកចិត្តវិទ្យា Indigo

ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា

របាយការណ៍សង្ខេប

ការសិក្សាថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធជីវិតរបស់ស្ត្រី គឺជាការស្ទាបស្ទង់មតិដែលផ្តែកលើប្រជាជនដំបូងបំផុត ដែលវាស់វែងលើអត្រាសាយភាយនៃបទពិសោធស្ត្រីចំពោះ អំពើហិង្សាលើស្ត្រី នៅក្នុងប្រទេសកម្ពុជា។ ការសិក្សានាពេលកន្លងមក បានចង្អុលបង្ហាញអំពីធម្មជាតិដ៏សាយភាយនៃអំពើហិង្សាលើស្ត្រីក្នុងប្រទេសកម្ពុជា ហើយការសិក្សានេះបានអះអាងពីភាពត្រឹមត្រូវនៃការស្រាវជ្រាវកន្លងមក (CDHS, 2012; Fulu et al., 2013)។



World Health Organization
Western Pacific Region

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

Australian Aid